December-2008.qxd 11/27/2008 6:08 PM Page 1

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-៣១ ខែធ្នូ ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ១៦

## មាតិកា



បទពិសោធន៍ក្រុមរបាំកុមារកម្ពុជានៅអេស្ប៉ាញ
ទំព័រ ៧



ឡាវ៉ាឡា : សាលាដែលផ្ដល់ក្ដីសង្ឃឹមដល់កុមារពិការ
ទំព័រ ៨



មហោស្រព រូបថតចម្រុះ
ទំព័រ ១៤

# កម្មករជំនាញ អាជីពមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍន៍

ទំព័រទី១០...



SIPAR
សៀវភៅ
ធ្វើអោយអ្នកចេះ
មានលក់នៅតាមបណ្ណាគារ
និងតូបលក់សៀវភៅនានា
023 216 001
siparedition@online.com.kh



កម្មវិធីវិទ្យុ


អេម៉ាន្វូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ ថ្ងៃ សៅរ៍/អាទិត្យ
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:០០-១៣:០០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតសម្រាប់លេខនេះ



hoto : L. Sovanna

នៅឆ្នាំនេះទិវាបុណ្យឯករាជ្យជាតិខួបលើកទី ៥៥ ត្រូវបានប្រារព្ធឡើងយ៉ាងអធិកអធមក្រៃលែង ក្រោមអធិបតី-ភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទនរោត្តមសីហមុនី មន្ត្រីរាជរដ្ឋា-ភិបាល និងប្រជាពលរដ្ឋចូលរួមយ៉ាងច្រើនកុះករ និងមានការដង្ហែក្បួននៃក្រសួង អាជ្ញាធរ ឬស្ថាប័នរដ្ឋនានា នៅមុខព្រះបរមរាជវាំង។ **(ឆ្វេង)**

---

ការសម្ពោធវិមានទស្សនវិស័យ និងបេសកកម្មរបស់វិទ្យាល័យសន្តប្រង់ស្វ័រ កាលពីថ្ងៃទី៣១ តុលា ឆ្នាំ២០០៨ នៅវិទ្យាល័យចំណេះទូទៅ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈសន្តប្រង់ស្វ័រនៅស្រុកត្រាំកក់ ខេត្តតាកែវ។ **(ក្រោម)**

នៅក្នុងឆ្នាំសិក្សាថ្មីនេះ វិទ្យាល័យសន្តប្រង់ស្វ័រ មានបើកទទួលសិស្សថ្នាក់ទី៧ថ្មី ជាមួយនិងការបំពាក់បណ្ដាញអ៊ីនធើណែតដែលបានទទួលការឧបត្ថម្ភពីសហគមន៍អឺរ៉ុប។ បណ្ដាញថ្មីនេះក៏ភ្ជាប់ជូនទៅវិទ្យាល័យអង្គរនាម និងវិទ្យាល័យ១ឧសភា ដើម្បីឱ្យសិស្សទាំងអស់មានឱកាសរៀនចំណេះដឹងថ្មីៗតាមប្រព័ន្ធនេះក្នុងពេលតែមួយ។ **(ក្រោម)**



hoto : L. Samphors



hoto : L. Samphors

ចាប់ពីថ្ងៃទី១ មករា ឆ្នាំ២០០៩តទៅ នឹងមានការផាកពិន័យចំពោះអ្នកមិនពាក់មួកសុវត្ថិភាព។ ការពាក់មួកសុវត្ថិភាពត្រឹមត្រូវបង្ហាញពីសេចក្ដីថ្លៃថ្នូររបស់ពលរដ្ឋដែលចេះគោរពច្បាប់ចរាចរណ៍។ **(ក្រោម)**



hoto : Tintin

បងស្រីជីនីស ប្រធានអង្គការជេអេសស៊ីកម្ពុជា ត្រូវបានបំពាក់រង្វាន់មេដាយការងារល្អ សម្រាប់ការងារមនុស្សធម៌របស់បងស្រីអស់រយៈពេលជាង ១៨ឆ្នាំ នៅកម្ពុជា កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅស្ថានទូតអូស្ត្រាលី។ **(ឆ្វេង)**



hoto : L. Samphors



# វិចារណកថា

## អត្ថន័យពិត នៃថ្ងៃបុណ្យព្រះយេស៊ូប្រសូត



hoto : . Samphy

**លោកបូជាចារ្យ អូមែរ ហ្ស៊ីរ៉ាល់ដូ ប្រធានមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក (CSC)**

រដូវបុណ្យព្រះយេស៊ូប្រសូត ប្រារព្ធធ្វើនៅក្នុងខែនេះគឺជាពេលសម្រាប់គ្រីស្តបរិស័ទរំឭកជំនឿអំពីព្រះជាម្ចាស់ដែលបានកើតជាមនុស្សតាមរយៈព្រះយេស៊ូគ្រីស្ត និងបានចែករំលែកនូវបទពិសោធន៍ដូចមនុស្សដទៃដែរ ទោះបីព្រះអង្គរស់នៅដោយការលំបាក ដូចគ្រីស្តទូតប៉ូល ដែលបានសរសេរក្នុងលិខិតមួយជូនគ្រីស្តបរិស័ទនៅក្រុងភីលីព(ភីលីព ២,១១) ក៏ដោយ។

នៅពាសពេញពិភពលោក ក៏ដូចជាប្រទេសកម្ពុជាដែរ ពុំមែនជាប្រទេសគ្រីស្តសាសនានោះ រដូវបុណ្យណូអែលគឺជាវេលាល្អសម្រាប់ជួញដូររកស៊ី និងធ្វើអាជីវកម្ម។ បាច់ផ្កាធំៗ និងមានពណ៌ផ្សេងៗគ្នា ធ្វើអំពីក្រដាសនៅតាមទីក្រុងនានា មានភ្លើងលម្អចម្រុះពណ៌ព្រោងព្រាត និងរូបសំណាកលោកតាណូអែលដែលមានសម្លៀកបំពាក់ពណ៌ក្រហមឆ្អិនឆ្អៅ ត្រូវបានគេដាក់តាំង។ ប្រជាជនបានអញ្ជើញមិត្តភក្តិ ដើម្បីទទួលទានអាហារជួបជុំគ្នា និងមានសកម្មភាពផ្សេងៗ ទៀតជាច្រើន។

ក្នុងបរិយាកាសនេះ មនុស្សជាច្រើនមានការភាន់ច្រឡំថា នេះគ្រាន់តែជាពេលវេលាកំសាន្តសប្បាយរវាងគ្នានឹងគ្នា ឬត្រៀមខ្លួនសម្រាប់ទទួលឆ្នាំសកលទៅវិញ ដែលវាផ្ទុយពីអត្ថន័យពិតរបស់គ្រីស្តសាសនា។ យើងដែលជាគ្រីស្តបរិស័ទសូមបដិសេធចំពោះការយល់ឃើញដូច្នេះ។ ការពិតបុណ្យណូអែលជាបុណ្យរំឭកព្រះយេស៊ូប្រសូតជាមនុស្ស។ ក្រុមគ្រីស្តបរិស័ទប្រារព្ធនូវពិធីបុណ្យនេះឡើងដោយមានអំណរសប្បាយ ពីព្រោះពួកគេជឿជាក់ថា ព្រះជាម្ចាស់យាងមកគង់នៅជាមួយពួកគេ។ ព្រះជាម្ចាស់ជាមនុស្ស ព្រះជាម្ចាស់គឺជាកុមារតូចម្នាក់ ហើយព្រះអង្គចែករំលែកបទពិសោធន៍ជាមនុស្ស ជាមួយអ្នកដទៃ។

ជាការពិត រឿងនេះហួសនឹងជឿ។ ប៉ុន្តែសម្រាប់យើងជាគ្រីស្តបរិស័ទ គឺមានភាសា សញ្ជាតិ សាសនា វប្បធម៌ ឬជាប្រទេសមានកិត្តិយស ការគោរព និងសេចក្ដីស្រលាញ់។

អ្នកនាំសារសូមគោរពអញ្ជើញជនជាតិខ្មែរដែលមានប្រពៃណីតាមព្រះពុទ្ធសាសនាដ៏មានតម្លៃ គឺកុំឱ្យធ្លាក់ក្នុងការអូសទាញនឹងសម្ភារៈនិយម នាឱកាសថ្ងៃបុណ្យណូអែលឱ្យសោះ។

**ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្ស៊ីរ៉ាល់ដូ។

ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៩ ថ្មី ដែលជាចម្រៀងពណ៌នាអំពីតង្វាយដែលថ្វាយទៅព្រះជាម្ចាស់។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ បើប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងលេខទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។/

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : ០១២ ៣៧៧ ៩៦០។/

**សារសម្រាប់មិត្តអ្នកអាន!**

បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ផ្ដល់មតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្ដល់នូវការឆ្លើយតបដោយក្ដីរីករាយ។



**សូមប្រិយមិត្តមើល និងកំសាន្តជាមួយល្បែងរូបភាព នៅទំព័រទី១៦ រួចមើលជំនួយគំនិតនេះៗ**

**សេចក្ដីជូនដំណឹង !** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយចំណេញបានច្រើន សូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។

បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ។/

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

**ថ្ងៃអាទិត្យ ទី២ រដូវរង់ចាំ (ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៨)**

*(ម៉ាកុស១,១-៨)* រដូវរង់ចាំ គឺជាពេលត្រៀមខ្លួនសម្រាប់ទទួលបុណ្យណូអែល ។ គ្រីស្តបរិស័ទប្រារព្ធពិធីបុណ្យព្រះយេស៊ូប្រសូតដែលព្រះបុត្រារបស់ព្រះជាម្ចាស់មកជាមនុស្សលោក ។ នៅអំឡុងរដូវរង់ចាំ យើងជាគ្រីស្តបរិស័ទ ចូលរួមអធិដ្ឋានចំពោះការយាងមករបស់ព្រះជាម្ចាស់ នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។ ព្យាការីអេសាយបានប្រកាសថា : "ព្រះអង្គនឹងថែរក្សាប្រជារាស្ត្ររបស់ព្រះអង្គដូចជាគង្វាលថែរក្សាហ្វូងចៀមរបស់ខ្លួន ។ ទ្រង់លើកព្រះហត្ថឡើងធ្វើសញ្ញា ប្រមូលកូនចៀម ។ ព្រះអង្គបីកូនចៀមតូចៗ ជាប់នឹងព្រះឧរា ហើយថែមទាំងមេចៀមដែលកំពុងបំបៅកូន" ។

នៅក្នុងសប្តាហ៍ទីពីរនៃរដូវរង់ចាំនេះ ព្រះសហគមន៍ចង់ឱ្យយើងត្រៀមខ្លួន និងស្តាប់រាល់ការប្រៀនប្រដៅរបស់យ៉ូហាន បាទីស្ត ដែលមករៀបចំផ្លូវថ្វាយព្រះយេស៊ូគ្រីស្ត ដែលជាព្រះបុត្រារបស់ព្រះបិតា ។

**ថ្ងៃអាទិត្យ ទី៣ រដូវរង់ចាំ (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៨)**

*(យ៉ូហាន១,៦-៨ & ១៩-២៨)* ព្រះបន្ទូលដំណឹងល្អថ្ងៃនេះ និយាយពីលោកយ៉ូហានបាទីស្ត ក្នុងព្រះគម្ពីរដំណឹងល្អ តែងដោយព្យាការីអេសាយថា : "ខ្ញុំជាសំឡេងមនុស្សម្នាក់ដែលស្រែកនៅវាលរហោឋាន ។ ចូរតម្រង់ផ្លូវថ្វាយព្រះជាម្ចាស់" ។ លោកយ៉ូនហាន បាទីស្ត កត់សម្គាល់ថា ខ្លួនគាត់មិនមែនជាព្រះយេស៊ូដែលជាស្តេចបានលាបប្រេង ដែលពួកគេកំពុងរង់ចាំនោះទេ ក៏ប៉ុន្តែលោកជាសាក្សីដែលមកពន្យល់ពីព្រះយេស៊ូគ្រីស្ត ។ ព្យាការីអេសាយពិពណ៌នាអំពីព្រះយេស៊ូជាព្រះជាម្ចាស់ដែលយាងមកដើម្បីនាំដំណឹងល្អទៅប្រាប់អ្នកដែលគេជិះជាន់ និងជួយថែរក្សាអ្នកដែលបាក់ទឹកចិត្ត និងប្រកាសប្រាប់ជនជាប់ជាឈ្លើយថា : "ពួកគេនឹងរួចខ្លួននិងមានសេរីភាព" ព្រមទាំងប្រកាសពី "ឆ្នាំដែលព្រះជាម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា" ផងដែរ ។ ព្រះគម្ពីរមានន័យថា យើងជាព្រះយេស៊ូ ជាដំណឹងល្អរបស់ព្រះជាម្ចាស់ទៅប្រាប់ដល់ជនក្រីក្រ ។

**ថ្ងៃអាទិត្យ ទី៤ ក្នុងរដូវរង់ចាំ (ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៨)**

*(លូកា១,២៦-៣៨)* ព្រះជាម្ចាស់យាងមកនៅក្នុងចំណោមយើងទាំងអស់គ្នាតាមរយៈរូបកាយស្ត្រី ដែលមានឋានៈតូចទាប ប៉ុន្តែបានបើកចិត្តគំនិតទទួលព្រះបន្ទូលដំណឹងល្អក្នុងជីវិតរបស់នាង ។

នៅពេលនាងម៉ារី យល់ព្រមជាមួយហ្គាប្រីល ដែលបញ្ជូនដោយព្រះជាម្ចាស់ដើម្បីសួរសុខទុក្ខនាង ។ នាងម៉ារីក៏បានជ្រើសយកព្រះជាម្ចាស់ ។ នាងម៉ារីទទួលយកគម្រោងការរបស់ព្រះជាម្ចាស់ក្នុងខ្លួននាង ទោះជានាងពុំដឹងច្បាស់ថា នឹងមានរឿងអ្វីកើតឡើងក៏ដោយ ។ ចម្លើយវិជ្ជមានរបស់នាងម៉ារីចំពោះបំណងប្រាថ្នារបស់ព្រះជាម្ចាស់ ជំរុញលើកទឹកចិត្តយើងឱ្យទទួលព្រះយេស៊ូគ្រីស្តក្នុងជីវិតរស់នៅរបស់យើងផងដែរ ។

**អបអរសាទរ! ថ្ងៃបុណ្យព្រះយេស៊ូប្រសូត (ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៨)**

*(យ៉ូហាន១,១-១៨)* សម្រាប់យើងដែលជាគ្រីស្តបរិស័ទ ព្រះជាម្ចាស់គង់នៅជិតបង្កើយនឹងមនុស្សដែលមានការឈឺចាប់ ។ រីឯការប្រសូតរបស់ព្រះយេស៊ូ ប្រជាជនអ៊ីស្រាអែលបានទទួលស្គាល់នូវការបំពេញព្រះបន្ទូល ។ ព្រះគម្ពីរព្យាការីអេសាយថា: "ប្រជាជនដែលដើរក្នុងភាពងងឹត នឹងបានឃើញពន្លឺមួយដ៏ចិញ្ចែងចិញ្ចាច ហើយមានពន្លឺមួយលេចឡើងបំភ្លឺអស់អ្នកដែលរស់នៅក្រោមអំណាចនៃសេចក្តីស្លាប់" ។ ពន្លឺនេះគឺជាព្រះយេស៊ូកុមារ ដែលជាបុត្រារបស់ព្រះបិតា ។ ព្រះជាម្ចាស់យាងមករស់នៅ ក្នុងចំណោមយើងទាំងអស់គ្នាជាមនុស្សលោកដើម្បីចែករំលែកបទពិសោធន៍ជាមនុស្សលោក ជាមួយនិងមនុស្សទន់ខ្សោយរហូតដល់ព្រះអង្គត្រូវចូលទិវង្គតនៅលើឈើឆ្កាង ។ នៅលើឈើឆ្កាងនេះ យើងជាគ្រីស្តបរិស័ទមើលឃើញយ៉ាងច្បាស់អំពីសិរីរុងរឿងរបស់ព្រះជាម្ចាស់ ។ រដូវបុណ្យណូអែលនេះ ជាវេលាអំណរសប្បាយ ។ ព្រះជាម្ចាស់សម្របសម្រួលយើងឱ្យក្លាយជាបុត្រធីតារបស់ព្រះអង្គ ។

**បុណ្យលើកតម្កើងព្រះរាជវង្ស (ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៨)**

*(លូកា២,២២-៤០)* នៅថ្ងៃអាទិត្យក្រោយបុណ្យណូអែល ព្រះសហគមន៍យើងនឹងប្រារព្ធពិធីបុណ្យលើកតម្កើងព្រះរាជវង្ស ។ ពិធីបុណ្យក្នុងប្រពៃណីគ្រីស្តសាសនា ជួយយើងឱ្យយល់ថា ព្រះកុមារយេស៊ូ ដែលជាព្រះបុត្រារបស់ព្រះបិតាធំធាត់ឡើង និងបានទទួលការអប់រំក្នុងគ្រួសារលោកយ៉ូសែប និងនាងម៉ារី ។ ព្រះយេស៊ូកើតជាមនុស្ស មានជីវិតក្នុងគ្រួសារដូចមនុស្សទូទៅ គឺរៀនដើរ រៀនអធិដ្ឋាន រៀនធ្វើការ និងរៀនទំនាក់ទំនងជាមួយមនុស្សដទៃ ។ ដូច្នេះជីវិតជាគ្រួសារ គឺមានសារៈសំខាន់នៅគ្រប់សង្គមទាំងអស់ ។ ក្រុមគ្រួសារនៃព្រះយេស៊ូកុមារជាគ្រួសារគំរូដ៏ល្អមួយ និងជាឧទាហរណ៍ប្រពៃសម្រាប់យើងជាគ្រីស្តបរិស័ទ ។

*(អ្នកនាំសារ ខែធ្នូ ២០០៨ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកបូជាចារ្យ អូមែរ ហ្សឺវ៉ាល់ដូ)*

## យើងអាន



hoto: D

**ប្អូនៗជាទីស្រឡាញ់!**

នៅក្នុងខែធ្នូនេះ គឺយើងចាប់ផ្តើមឆ្នាំថ្មីតាមប្រតិទិនក្នុងព្រះសហគមន៍កាតូលិក។ យើងចាប់ផ្តើមឆ្នាំថ្មីជាមួយនិងរដូវរង់ចាំ (រដូវអបអរសាទរបុណ្យព្រះយេស៊ូប្រសូត)។

ដូច្នេះតើប្អូនៗបានត្រៀមខ្លួនហើយឬនៅ? តើយើងរៀបចំទទួលព្រះយេស៊ូដូចម្តេច? តើព្រះយេស៊ូនឹងប្រសូតម្តងទៀតដែរឬ? តាមពិត ព្រះយេស៊ូបានប្រសូតមកជាមនុស្សជាង ២០០០ឆ្នាំមកហើយ។ តែការរៀបចំចិត្តគំនិតរបស់យើងនៅក្នុងរដូវរង់ចាំនេះ គឺរង់ចាំថាព្រះអង្គនឹងយាងមកនៅថ្ងៃណាមួយម្តងទៀត។ នៅក្នុងរដូវរង់ចាំនេះ គឺរំឭកយើងកុំឱ្យភ្លេចខ្លួន ត្រូវចេះនឹកគិតដល់ព្រះជាម្ចាស់។ មិនត្រូវគិតតែពីជីវិត និងប្រយោជន៍ផ្ទាល់ខ្លួនទេ តែត្រូវចេះនឹកគិតដល់បងប្អូនឯទៀតៗផងដែរ។ ព្រះជាម្ចាស់ស្រលាញ់យើងទាំងអស់គ្នាខ្លាំងណាស់ហួសពីការស្មានរបស់យើងជាមនុស្ស។ ព្រះអង្គជ្រើសរើសប្អូនៗតាមឈ្មោះម្នាក់ៗ។ ដូច្នេះសូមប្អូនៗរួមចិត្តគំនិតជាមួយព្រះសហគមន៍ដើម្បីសម្តែងនូវសក្ខីភាពអំពីសេចក្តីស្រឡាញ់ទាំងប៉ុន្មាន ដែលប្អូនៗបានទទួលនេះទៅកាន់មិត្តភក្តិនៅក្នុងសាលាក្នុងភូមិ និងគ្រប់ទីកន្លែងដែលប្អូនរស់នៅ។ គ្រីស្តទូតប៉ូលសរសេរថា : "រួមជាមួយព្រះអង្គ បងប្អូនបានបរិបូរណ៍គ្រប់ទាំងអស់ ទាំងព្រះបន្ទូល និងទាំងការស្គាល់ព្រះអង្គ។ សក្ខីភាពរបស់ព្រះគ្រីស្តបានស្ថិតនៅក្នុងបងប្អូនយ៉ាងខ្ជាប់ខ្ជួន។ ហេតុនេះហើយ នៅពេលដែលបងប្អូនកំពុងរង់ចាំព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់របស់យើងយាងមកយ៉ាងរុងរឿងនោះ បងប្អូនមិនខ្វះព្រះអំណោយទានអ្វីឡើយ"។

ដូច្នេះនៅក្នុងរដូវរង់ចាំនេះ សូមប្អូនៗយកចិត្តទុកដាក់រៀបចំផ្លូវថ្វាយព្រះអម្ចាស់យេស៊ូដែលយាងមកក្នុងជីវិតរស់នៅយើងដោយសមរម្យ។ សូមព្យាយាមសម្រុះសម្រួលជាមួយមិត្តភក្តិដែលមិនចុះសម្រុងនឹងប្អូន។ ខិតខំរស់នៅដោយស្តាប់បង្គាប់ឪពុកម្តាយ លោកគ្រូអ្នកគ្រូ ជាពិសេសយកចិត្តទុកដាក់ក្នុងការសិក្សាដើម្បីក្លាយជាកូនល្អ សិស្សល្អ និងជាកុមារកាតូលិកគំរូផងដែរ។

លី សុវណ្ណា



# ព័ត៌មានទូទៅ



hoto: L. Sivanna

## សម្តេចហ៊ុន សែន : កម្ពុជាធានាបានសុខសន្តិភាព និងប្រាង្គប្រាសាទជូនប្រជាពលរដ្ឋ

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសក្នុងទិវាខួបឯករាជ្យជាតិ និងថ្ងៃកំណើត កងយោធពលខេមរភូមិន្ទ លើកទី៥៥ មុខព្រះបរមរាជវាំង ដែលមានការចូលរួមពីសំណាក់កងកម្លាំងមន្ត្រី រាជការគ្រប់ស្ថាប័ន និងសិស្សានុសិស្សរាប់ម៉ឺននាក់ ថា កងកម្លាំង កម្ពុជាបច្ចុប្បន្នកំពុងតែបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តម ដោយរក្សាបាននូវសុខសន្តិភាព និងសេចក្តីសុខជូនប្រជាជនរួមទាំងប្រាង្គប្រាសាទទាំងឡាយ ឱ្យរួចផុតពីការរំលោភបំពានឈ្លានពានពីបរទេស ។ នេះជាប្រសាសន៍ជាសាធារណៈលើកដំបូង ក្រោយពេលដែលប្រទេសកម្ពុជាបានទទួលរងនូវការឈ្លានពានពីសំណាក់កងទ័ពសៀម នៅតំបន់ប្រាសាទព្រះវិហារ ចាប់តាំងពីថ្ងៃទី ១៥ កក្កដា ក្រោយពេលដែលប្រាសាទព្រះវិហារត្រូវបានចុះបញ្ជីទៅក្នុងបេតិកភណ្ឌពិភពលោក នៅថ្ងៃទី៧ កក្កដា កន្លងទៅ ។

## ឯកឧត្តមហុក ឡង់ឌី បាត់បង់ជីវិតនៅក្នុងឧប្បត្តិហេតុធ្លាក់ឧទ្ធម្ភាគចក្រ

ឧត្តមសេនីយ៍នគរបាលផ្កាយមាស៤ ហុក ឡង់ឌីដែលជាដំនួងរបស់សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានទទួលគ្រោះថ្នាក់បាត់បង់ជីវិតក្នុងអាយុ ៥១ឆ្នាំ ដោយឧប្បត្តិហេតុធ្លាក់ឧទ្ធម្ភាគចក្រកាលពីយប់ថ្ងៃអាទិត្យ ទី៩ វិច្ឆិកា ក្នុងស្រុករំដួល ខេត្តស្វាយរៀង ខណៈពេលដំណើរបេសកកម្ម ពីទីក្រុងភ្នំពេញទៅខេត្តស្វាយរៀង ។ អ្នកដំណើរ ៤រូបក្នុងឧទ្ធម្ភាគចក្រនោះ គ្មាននរណាម្នាក់រួចជីវិតឡើយ ទាំងឯកឧត្តមហុក ឡង់ឌី លោកសុខសាឯម ឧត្តមសេនីយ៍ ផ្កាយ៣ កងទ័ពជើងគោក និងអាកាសយានិក ២ រូបទៀត ។ មិនមានការបញ្ជាក់ផ្លូវការណាមួយអំពីមូលហេតុនៃគ្រោះថ្នាក់ធ្លាក់ឧទ្ធម្ភាគចក្រនេះនៅឡើយទេ ។ លោកសុខ ផល អគ្គស្នងការរងនគរបាលជាតិ បានបញ្ជាក់យ៉ាងខ្លីថា សមត្ថកិច្ចកំពុងតែស៊ើបអង្កេតរឿងនេះ ។ ឯកឧត្តមហុក ឡង់ឌី បានឡើងកាន់មុខតំណែងអគ្គស្នងការនគរបាលជាតិនេះ តាំងពីឆ្នាំ១៩៩៤ មកម្លេះ ។ សពឯកឧត្តមហុក ឡង់ឌី ត្រូវបានដង្ហែទៅបញ្ចុះនៅក្នុងភូមិគ្រឹះ ដែលជាស្រុកកំណើតរបស់ឯកឧត្តមនៅឯខេត្តស្វាយរៀង ។

## សូគីម៉ិច និងតេលា បញ្ចុះតម្លៃប្រេងភ្លាមៗ តាមការអំពាវនាវរបស់នាយករដ្ឋមន្ត្រី

អន្តរាគមន៍របស់សម្តេចហ៊ុន សែន ពីខេត្តកណ្តាល កាលពីព្រឹកថ្ងៃច័ន្ទ ទី១៧ វិច្ឆិកានេះ បានធ្វើឱ្យតម្លៃប្រេងសាំងនៃក្រុមហ៊ុនសូគីម៉ិច និងកម្ពុជាតេលា ចុះថ្លៃ ២០០រៀល និង ១៥០រៀល ក្នុងមួយលីត្រ ។ ការបញ្ចុះតម្លៃប្រេងនេះ ធ្វើឡើងតាមការបញ្ជាពីនាយករដ្ឋមន្ត្រី ឱ្យធ្វើការទំនាក់ទំនងដោយផ្ទាល់តាមទូរស័ព្ទទៅកាន់ប្រធានក្រុមហ៊ុនទាំងពីរ ក្នុងពេលធ្វើសុន្ទរកថារបស់សម្តេច នាពិធីសម្ពោធក្រុមហ៊ុនជីវឥន្ធនៈរបស់ប្រទេសកូរ៉េនៅខេត្តកណ្តាល ។ សម្តេចនាយកបានិរិះគន់ចំពោះក្រុមហ៊ុនប្រេងឥន្ធនៈបរទេស មានកាល់តិច តូតាល់ ប៉េត្រូណាស់ និង PTT ដែលមិនមានចេតនាបញ្ចុះតម្លៃ ពេលដែលតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិបានធ្លាក់ចុះហើយនោះ ។

រស់ ឌីណា

## ប្រធានាធិបតីថ្មីរបស់សហរដ្ឋអាម៉េរិក ជាជនស្បែកខ្មៅ



hotos: D

ពលរដ្ឋអាម៉េរិកបានសម្រេចជ្រើសរើសប្រធានាធិបតីជនស្បែកខ្មៅ ជាលើកទីដំបូង ក្នុងការបោះឆ្នោតជាប្រវត្តិសាស្ត្រ កាលពីដើមខែវិច្ឆិកា កន្លងទៅ ដើម្បីបន្តវេនពីលោកចច ដាប់បែលយូ ប៊ូស ដែលនឹងត្រូវបញ្ចប់អាណត្តិ នៅចុងខែមករា ឆ្នាំ ២០០៩ ខាងមុខ ។

បណ្តាញព័ត៌មានស៊ីអេនអេន បានរាយការណ៍ថា អ្នកដែលប្រជាពលរដ្ឋអាម៉េរិក បានជ្រើសរើសធ្វើអ្នកដឹកនាំរបស់ខ្លួន គឺលោកបារ៉ាក់ អូបាម៉ា ដែលមានម្តាយជាជនជាតិអាម៉េរិក ហើយឪពុកគឺជាជនជាតិស្បែកខ្មៅនៅក្នុងប្រទេសកេនយ៉ា ។ លោកអូបាម៉ា ជាព្រឹទ្ធសមាជិករដ្ឋអ៊ីលីណយ ដែលមកពីគណបក្សប្រជាធិបតេយ្យ បានយកឈ្នះលើបេក្ខជនប្រធានាធិបតីមកពីគណបក្សសាធារណរដ្ឋ គឺលោកចន ម៉ាកខេន យ៉ាងងាយស្រួលកាលពីពេលបោះឆ្នោតកន្លងមក ។

ប្រភពដដែលនោះបានឱ្យដឹងថា លោកនឹងចូលកាន់តំណែង នៅដើមឆ្នាំ ២០០៩ ខាងមុខ ជាមួយនិងកិច្ចការធំៗ ជាច្រើនដែលត្រូវដោះស្រាយ មានវិបត្តិហិរញ្ញវត្ថុអន្តរជាតិ ភេរវកម្ម សង្គ្រាមនៅអ៊ីរ៉ាក់ អាហ្គានីស្ថង់ និងបញ្ហារត់ប្រណាំងសព្វាវុធជាមួយនឹងប្រទេសរុស្ស៊ី-ល- ។

## អ៊ីរ៉ង់សាកល្បងមីស៊ីលថ្មីជោគជ័យ



ប្រទេសអ៊ីរ៉ង់ដែលជាសធារណរដ្ឋអ៊ីស្លាម១ បានប្រកាសថា ខ្លួនបានសាកល្បងមីស៊ីល ដែលអាចបាញ់បានរយៈចម្ងាយមធ្យមបានជោគជ័យកាលពីថ្ងៃទី១២ ខែវិច្ឆិកា កន្លងទៅថ្មីៗនេះ ។

លោកឧត្តមសេនីយ៍មូស្តាហ្វាមូហាម៉េត ណៃហ្សារដ្ឋមន្ត្រីការបទេសរបស់អ៊ីរ៉ង់អះអាងថា នេះគឺជាប្រភេទមីស៊ីលថ្មីដែលមានសមត្ថភាពបាញ់បានរហូតដល់២០០០គ.ម ដែលអ្នកវិទ្យាសាស្ត្ររបស់ខ្លួនបានផលិតមកបានយ៉ាងជោគជ័យ ។

នៅក្នុងសេចក្តីប្រកាសទៅតាមប្រព័ន្ធផ្សព្វផ្សាយជាតិខ្លួន លោកមូស្តាហ្វា ក៏បន្តថា មីស៊ីលថ្មីនេះមានឈ្មោះមីស៊ីលសាអ៊ីល ដែលងាយស្រួលផលិត អាចបាញ់បានលឿន និងចំគោលដៅ ។ មីស៊ីលនេះ មានអង្កត់ផ្ចិតប្រមាណជា១,២៥ម ហើយជាប្រភេទមីស៊ីលថ្មី ដែលអ៊ីរ៉ង់បានផលិតចេញ ហើយក៏ដាក់ឈ្មោះដូច្នេះ បន្ទាប់ពីប្រទេសនេះធ្លាប់បរាជ័យម្តងកាលពីខែវិច្ឆិកា ឆ្នាំ២០០៧ ។

បើតាមអ្នកវិភាគអន្តរជាតិបានឱ្យដឹងថា ប្រសិនបើអ្វីដែលអ៊ីរ៉ង់បានអះអាងពិតប្រាកដមែននោះ មីស៊ីលប្រភេទនេះគឺជាមីស៊ីលដែលវាអាចឱ្យគេបាញ់ដល់ប្រទេសអ៊ីស្រាអែល ព្រមទាំងមូលដ្ឋានរបស់កងទ័ពអាម៉េរិកនានានៅក្នុងតំបន់មជ្ឈិមបូព៌ាបាន ។

ខាន់ ភិរម្យ

December-2008.qxd 11/27/2008 6:08 PM Page 6



# “យុវជនត្រូវស្គាល់ខ្លួនឯង និងស្គាល់ជីវិតគ្រីស្តទូតប៉ូល”

**ឡុង សម្ផស្ស**

យុវជនយុវនារីចំនួន៨៥នាក់ ដែលមកពីព្រះសហគមន៍ ទាំងប្រាំ ស្ថិតនៅក្នុងមណ្ឌលសកម្មភាព ខេត្តកំពត រួមមានព្រះសហគមន៍ត្រពាំងល្ពៅ ព្រៃប្រស់ កោះស្លា ជុំគីរី និងកំពត បានជួបជុំគ្នានៅក្នុងសិក្ខាសាលាមួយ អំពីប្រធានបទ : “យុវជនយុវនារីត្រូវស្គាល់ខ្លួនឯង និងស្គាល់ជីវិតគ្រីស្តទូតប៉ូល” ។ សិក្ខាសាលានេះប្រារព្ធធ្វើឡើង នៅមជ្ឈមណ្ឌលវប្បធម៌កាតូលិកកំពតកាលពីថ្ងៃទី ២២-២៣ ខែវិច្ឆិកា ឆ្នាំ ២០០៨ កន្លងទៅនេះ ។

លោក ផុន សុផល អ្នកដឹកនាំសិក្ខាសាលានេះ បានឱ្យដឹងថា : “សិក្ខាសាលានេះផ្តោតទៅលើចំណុចពីរសំខាន់ គឺទី១ ឱ្យយុវជនយុវនារីស្គាល់ពីខ្លួនឯង និងស្គាល់គ្រីស្តទូតប៉ូល និងចេះឆ្លើយទៅនឹងតម្រូវការរបស់ព្រះសហគមន៍ ។ ទី២ ឱ្យយុវជនយុវនារី ទាំងអស់ស្វែងយល់ពីសកម្មភាព ដែលខ្លួនត្រូវធ្វើ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះ ។ ប៉ុន្តែយើងចង់បានអំពីរបៀបបង្កើតក្រុមយុវជនដែលល្អប្រសើរ ។

លោកបូជាចារ្យអ៊ុន សុន ទទួលខុសត្រូវព្រះសហគមន៍កំពត មានប្រសាសន៍ថា: “សិក្ខាសាលានេះជាលើកទី១ ដែលយើងរៀបចំឡើងសម្រាប់ភូមិភាគភ្នំពេញ ហើយនេះជាការផ្តល់ឱកាសឱ្យដល់យុវជនយុវនារីបានជួបជុំគ្នា និងស្គាល់ពីគ្នា ។ សិក្ខាសាលានេះអាចជួយឱ្យពួកគេម្នាក់ៗ ចេះស្គាល់ខ្លួនឯង និងស្គាល់ពីព្រះសហគមន៍ ។ យើងជួយពួកគេឱ្យចេះរិះគិត និងស្គាល់ពីជីវិតរបស់គ្រីស្តទូតប៉ូល ដើម្បីយកលោកធ្វើជាគំរូសម្រាប់ជីវិត” ។ លោកអ៊ុន សុន ក៏បញ្ជាក់បន្ថែមថា ការគោរពប្រតិបត្តិជំនឿគឺជាការអនុវត្តផ្ទាល់ និងជាការចូលរួមពីយើងម្នាក់ៗ ព្រមទាំងការជួយគាំទ្រគ្នាទៅវិញទៅមកនោះផង ។

ចំណែកកញ្ញានាវ ស្រីនាង អាយុ ១៩ឆ្នាំ មកពីព្រះសហគមន៍ជុំគីរី មានចំណាប់អារម្មណ៍ថា : “សិក្ខាសាលានេះជួយខ្ញុំឱ្យមើលឃើញអំពីចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងជីវិតខ្ញុំ ម្យ៉ាងទៀតធ្វើឱ្យខ្ញុំដឹងថា ជីវិតរបស់ខ្ញុំមានទំនាក់ទំនងជាមួយជីវិតគ្រីស្តទូតប៉ូលនៅក្នុងការប្រកាសដំណឹងល្អ ។ សម្រាប់ខ្ញុំ សិក្ខាសាលានេះបានផ្តល់នូវបទពិសោធន៍ដ៏ល្អ” ។


hoto : L. Samphors

យុវជនយុវនារីដែលមកពីព្រះសហគមន៍ទាំងប្រាំក្នុងមណ្ឌលសកម្មភាពកំពត ចូលរួមក្នុងសិក្ខាសាលាស្តីអំពី “យុវជនយុវនារីត្រូវស្គាល់ខ្លួន និងស្គាល់ជីវិតរបស់គ្រីស្តទូតប៉ូល”

## សិក្ខាសាលាពង្រឹងសមត្ថភាពគ្រូសាលាមត្តេយ្យ

កាលពីថ្ងៃទី២០-២២ វិច្ឆិកា ឆ្នាំ២០០៨ កន្លងទៅនេះ នៅព្រះវិហារសន្តយ៉ូសែប នារាជធានីភ្នំពេញ មានរៀបចំសិក្ខាសាលាមួយស្តីអំពីការពង្រឹងសមត្ថភាពរបស់គ្រូមត្តេយ្យ ។ អង្គសិក្ខាសាលានេះ មានការចូលរួមពីសំណាក់លោកគ្រូ អ្នកគ្រូ៥២នាក់ ដែលបានអញ្ជើញមកពីសាលាមត្តេយ្យរបស់ព្រះសហគមន៍កាតូលិក នៅភូមិភាគភ្នំពេញ និងបណ្តាអង្គការមួយចំនួន ។ សិក្ខាសាលានេះ រៀបចំដោយអង្គការ UFER ដោយសហការជាមួយនិងគណៈកម្មការព្រះសហគមន៍សម្រាប់ការអប់រំ ។ លោកបូជាចារ្យ អូលីវីយេ ជ្មិតហស្លេ ប្រធានគណៈកម្មការនេះ ក៏មានប្រសាសន៍ថា : “សិក្ខាសាលាដែលកំពុងប្រារព្ធធ្វើនេះ ជាលើកទី១៣ ហើយ ។ កម្មវិធីនេះជួយដល់លោកគ្រូ អ្នកគ្រូ ទាំងអស់ឱ្យកាន់តែមានសមត្ថភាពក្នុងការបង្រៀនដល់កុមារសាលាមត្តេយ្យនានារបស់ព្រះសហគមន៍ ។

**ឡុង សម្ផស្ស**


hoto : L. Samphors

# កិច្ចប្រជុំរវាងដៃគូសហការរបស់អង្គការការីតាស


hoto : S hlong

អង្គការការីតាសបានរៀបចំកិច្ចប្រជុំរវាងដៃគូរបស់ខ្លួន នៅឯការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះហគមន៍កាតូលិកកម្ពុជានាទីក្រុងភ្នំពេញ។ កិច្ចប្រជុំនេះ មានការចូលរួមពីសមាជិកជាដៃគូការីតាសទាំង៨ខេត្ត-ក្រុង ក្នុងរួមមានខេត្តតាកែវ កណ្តាល សៀមរាប ព្រះវិហារ បាត់ដំបង កំពង់ចាម ភ្នំពេញ និងកំពង់ធំ។ លោក នុត សំអុល នាយកប្រតិបត្តិរបស់អង្គការការីតាស មានប្រសាសន៍ថា កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលដៅពីរ : ទីមួយដើម្បីបញ្ជាក់ពីតម្លាភាពរវាងអង្គការការីតាសកម្ពុជា ដែលជាអ្នកអនុវត្តគម្រោង និងបណ្តាដៃគូមួយចំនួននៅលើពិភពលោក។ គោលដៅទី២ គឺជួយជំរុញលើកទឹកចិត្តដល់ដៃគូការីតាសឱ្យមានសកម្មភាពចូលរួម លើសពីការផ្តល់ជាប្រាក់ជំនួយ ដោយបូករួមទាំងការបញ្ចេញមតិយោបល់ និងការសម្រេចចិត្តដើម្បីទទួលលទ្ធផលមួយដ៏ប្រសើររួមគ្នា។

ចំណែកលោកសួ សុខគង់ ជាប្រធានកម្មវិធីអភិវឌ្ឍន៍សហគមន៍នៅក្នុងស្រុកសង្គមថ្មី ខេត្តព្រះវិហារ បានមានប្រសាសន៍ថា លោកពិតជាមានអារម្មណ៍រីករាយណាស់ ព្រោះការប្រជុំនេះបានផ្តល់ឱ្យលោកនូវចំណេះដឹងថ្មីជាច្រើនតាមរយៈការចែករំលែកនូវបទពិសោធន៍ពីដៃគូការីតាសទាំងក្នុង និងក្រៅប្រទេស។

រីឯអ្នកស្រីឆាន់ ហន ប្រធានអភិវឌ្ឍន៍សហគមន៍មួយក្នុងខេត្តសៀមរាប រៀបរាប់ថា ទោះបីជាគម្រោងរបស់អង្គការការីតាស មិនបានទទួលលទ្ធផល១០០% ក៏ដោយ ប៉ុន្តែអ្វីដែលជាទីកត់សម្គាល់នោះ គឺមានការផ្លាស់ប្តូរនូវឥរិយាបទរបស់សហគមន៍ទាំងផ្នែកស្មារតី និងការបញ្ចេញមតិរបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍សហគមន៍ផ្ទាល់របស់ខ្លួន។ *អាគន*





# បទពិសោធន៍ក្រុមរបាំកុមារកម្ពុជានៅអេស្ប៉ាញ

**ហ៊ួ សុខធារី**

ព្រះសហគមន៍តាហែន ស្ថិតនៅភូមិភាគបាត់ដំបង បានបញ្ជូនក្រុមរបាំបុរាណខ្មែររបស់កុមារ និងយុវជនពិការប្រចាំព្រះសហគមន៍នេះ កាលពីពេលថ្មីៗ ដើម្បីទៅធ្វើទស្សនកិច្ច និងសម្តែង រយៈ៦សប្តាហ៍ នៅប្រទេសអេស្ប៉ាញ ដែលដំណើរនេះបានការដឹកនាំពីលោកអភិបាលគីកេ ហ្វីហ្គារ៉េដូ ។

ក្នុងដំណើរទៅកាន់ប្រទេសអេស្ប៉ាញ ចាប់ពីថ្ងៃទី ៥ តុលា រហូតដល់ថ្ងៃទី៥ វិច្ឆិកា កុមារ និងយុវជនប្រមាណ ៧០ នាក់ ក្នុងនោះមានកុមារ និងយុវជនពិការចំនួន ១៥នាក់ បានសម្តែងរបាំនៅតាមទីក្រុងសំខាន់ៗ ប្រមាណជា ២០លើក ។

បើតាមប្រសាសន៍របស់លោកអាល់វ៉ារ៉ូ ហ្វីហ្គារ៉េដូ អ្នកជួយរៀបចំដំណើរទស្សនកិច្ច បានឱ្យដឹងដែរថា សិស្សានុសិស្សនៅប្រទេសអេស្ប៉ាញ បានស្វាគមន៍ និងរីករាយជាខ្លាំងចំពោះការសម្តែងរបស់ក្រុមរបាំយើង ។ លោកបន្តថា: “ពេលជនជាតិអេស្ប៉ាញសួរថា អ្នកចូលចិត្តអ្វីបំផុតនៅទីនេះ? យើងឆ្លើយថា គឺប្រជាជនអេស្ប៉ាញដែលយើងចូលចិត្តបំផុត” ។

សំ បទុមមិនដែលចេញមកក្រៅប្រទេសទេ ។ នាងបានរៀបរាប់ដែរថា : “នាងខ្ញុំមានអារម្មណ៍រីករាយជាខ្លាំង នៅពេលបានសម្តែងរបាំជូនពរនៅប្រទេសអេស្ប៉ាញ ។ ខ្ញុំធ្លាប់គិតថា ខ្ញុំពុំអាចសម្តែងរបាំបានឡើយ ក៏ប៉ុន្តែឥឡូវនេះ នាងខ្ញុំអាចធ្វើបាន ទោះបីជានាងខ្ញុំអង្គុយនៅលើរទេះរុញក៏ដោយ” ។

កុមារីម្នាក់ទៀត ឈ្មោះពិន អាយុ ៦ឆ្នាំ និយាយថា ក្នុងនាមនាងជាជនពិការម្នាក់ នាងក៏មានអារម្មណ៍សប្បាយរីករាយ និងមានមោទនភាពជាខ្លាំង ដែលបានសម្តែងរបាំបុរាណខ្មែរនៅទីនោះ ទោះវាជាការលំបាកសម្រាប់នាង ។ នាងបន្ថែមថា : “នាងខ្ញុំអាចជួយប្រទេសរបស់នាងខ្ញុំបានតាមរយៈ ឱ្យប្រជាជននៅក្រៅប្រទេសបានស្គាល់ និងបានដឹងអំពីអ្វីដែលល្អៗ នៅក្នុងប្រទេសរបស់នាងខ្ញុំ” ។

ជាម មិច អាយុ ៤៩ឆ្នាំ អ្នកទទួលខុសត្រូវក្រុមរបាំ មានយោបល់ថា : “យើងមិនមែនទៅទីនោះ ដើម្បីសម្តែងរបាំបុរាណខ្មែរតែមួយមុខទេ តែយើងក៏ធ្វើជាសាក្សីរបស់ព្រះជាម្ចាស់ ព្រមទាំងជំនឿនៃព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាផងដែរ ។

លោកអាល់ហ្វុងសូ ហ៉្គុងហ្សាលេហ្ស ហ្គាស្យ៉ា អ្នកស្ម័គ្រចិត្តជួយកុមារ និងយុវជន កម្ពុជា ក្នុងដំណើរទស្សនកិច្ចនេះ ក៏ចាប់អារម្មណ៍ដែរថា : “ខ្ញុំមានការកោតសរសើរជាខ្លាំង សម្រាប់ក្រុមរបាំបុរាណខ្មែរ ដែលចេះរួមគ្នា ជាមួយកុមារពិការដទៃទៀត និងសម្តែងបានយ៉ាងល្អដូច្នេះ ។ ម្យ៉ាងទៀត ខ្ញុំសង្កេតឃើញថា កុមារកម្ពុជាក៏ចេះគោរពចាស់ទុំ ចេះឱនលំទោន ហើយចេះជួយគ្នាទៅវិញទៅមកទៀត” ។

គួរបញ្ជាក់ថា ក្នុងអំឡុងទស្សនកិច្ចសិក្សានេះ ក្រុមរបាំបុរាណរបស់កុមារ និងយុវជនពិការខ្មែរ ក៏បានប្រមូលថវិកាជំនួយគ្រប់គ្រាន់ ឱ្យគម្រោងការចំនួនពីរនៅតាមជនបទភូមិភាគបាត់ដំបង ដើម្បីគាំពារក្មេងៗដែលមានជីវភាពក្រីក្រផងដែរ ។

## ដំណើរទស្សនកិច្ចនេះមានអត្ថន័យមួយ

**នេះមានន័យថា ជាការផ្ទេរអំណាចឱ្យកុមារពិការ និងជាការផ្សព្វផ្សាយអំពីវប្បធម៌ខ្មែរផង។ សកម្មភាពនេះ គឺគ្រាន់តែជាកិច្ចការមួយដែលព្រះសហគមន៍កាតូលិកបានធ្វើក្នុងចំណោមកិច្ចការជាច្រើន តាំងពីការរស់រានមានជីវិតថ្មីរបស់ព្រះសហគមន៍កាតូលិកក្នុងចំណោមប្រជាជនកម្ពុជា រួមទាំងក្រុមជនជាតិភាគតិចដ៏ច្រើនលើសលប់ដែលប្រតិបត្តិព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។ ការរស់រាននេះមានចាប់តាំងពីឆ្នាំ១៩៩០ និងបន្ទាប់ពីសង្គ្រាមស៊ីវិល និងការគំរាមកំហែងលើសាសនាអស់រយៈពេលជាងពីរទសវត្សរ៍ក្នុងប្រទេសកម្ពុជា។**


hoto : L. Samphors

December-2008.qxd 11/27/2008 6:08 PM Page 8



# ឡាវ៉ាឡា : សាលាផ្តល់ក្តីសង្ឃឹមដល់កុមារពិការ

**ឡុង សម្ផស្ស**


សិស្សត្រងត្រាប់ស្តាប់គ្រូក្នុងថ្នាក់សាលាឡាវ៉ាឡា

hotos : L. Samphors

ឡាវ៉ាឡា គឺជាឈ្មោះសាលាមួយដែលកំពុងតែជួយកុមារពិការ លើការសិក្សាកម្រិតបឋម គឺជួយផ្តល់ឱ្យពួកគេនូវចំណេះដឹងជាមូលដ្ឋាន ដើម្បីអាចរៀបចំជីវិតរបស់ខ្លួនឱ្យបានល្អប្រសើរនាពេលអនាគត ។ សាលានេះបានបង្កើតឡើងដោយអង្គការម៉ារីស្ស-មិស្សិនមកពីប្រទេសអូស្ត្រាលី ។

លោកឆោមសុបញ្ញា ជាអ្នកទទួលខុសត្រូវទូទៅនៃសាលាឡាវ៉ាឡា មានប្រសាសន៍ឱ្យដឹងថា : "ក្រុមគ្រួសារបងប្រុសម៉ារីស្សបានមកដល់ប្រទេសកម្ពុជានៅឆ្នាំ១៩៩៥ ហើយក៏បានចាប់ផ្តើមកម្មវិធីសាលាឡាវ៉ាឡានេះនៅថ្ងៃទី២២ មិថុនា ឆ្នាំ១៩៩៨ ។ នេះគឺជាកម្មវិធីដែលបានជ្រើសរើសយកគម្រោងជួយកុមារពិការទៅលើផ្នែកអប់រំ ដែលកុមារទាំងនោះមានស្ថានភាពពិការដូចជាពិការអវៈយវៈ និងមានបញ្ហាខួរក្បាល ដែលវាបណ្តាលមកពីជំងឺពីកំណើត ឬដោយគ្រោះថ្នាក់ចរាចរណ៏ ។ គម្រោងនេះក៏បានជួយផងដែរ ដល់ក្រុមសិស្សពិការដែលបោះបង់ការសិក្សា ដោយជួយពួកគេនោះឱ្យបានទទួលការអប់រំឡើងវិញ ឬបានទៅក្នុងសាលារដ្ឋវិញ ក្រោយពីពួកគេបានបញ្ចប់ការសិក្សា នៅទីនោះ ។ គម្រោងនេះបង្កើតឡើងនៅក្នុងគោលបំណងផ្តល់ការអប់រំដល់កុមារពិការដោយយើងមើលឃើញថា កុមារពិការជាជនងាយរងគ្រោះ ។ យើងក៏ជួយផ្តល់ឱកាសដល់កុមារពិការទាំងនោះទទួលបាននូវតម្លៃនិងសិទ្ធិស្មើភាពគ្នាក្នុងការទទួលបានការអប់រំ" ។

លោកបញ្ញា បានគូសបញ្ជាក់ថា : "សាលាឡាវ៉ាឡាមិនតម្រូវឱ្យយកបរិមាណសិស្សនោះទេ គឺគិតដល់គុណភាពនៃការអប់រំជាចម្បង ដូចជានៅក្នុងមួយថ្នាក់ៗ មានសិស្សចំនួនពី៩ ទៅ១៧នាក់ ប៉ុណ្ណោះ ។ សាលាក៏បានអនុវត្តតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ ព្រមទាំងបន្ថែមចំណេះដឹងផ្សេងៗទៀត ដល់សិស្សផងដែរ ។ សព្វថ្ងៃ សាលាមានត្រឹមតែកម្រិតបឋមសិក្សាប៉ុណ្ណោះ មានថ្នាក់ទី១ ដល់ទី៦ ដោយចែកជា ៨ថ្នាក់ ហើយឆ្នាំសិក្សាថ្មីនេះ សាលាទទួលសិស្សចំនួន ៩៨នាក់ ក្នុងនោះ សិស្ស ៧២នាក់ ត្រូវស្នាក់នៅក្នុងសាលា និង ២៦នាក់ទៀត គឺស្នាក់នៅខាងក្រៅ ។ សព្វថ្ងៃនេះសាលាឡាវ៉ាឡាមានទីតាំងស្ថិត នៅក្នុងភូមិព្រៃករាំង ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល ។ សូមទំនាក់ទំនងតាមទូរស័ព្ទលេខ : ០១២ ៨០៤២០៦ ។

# អ៊ុន ចាន់ណា : "ខ្ញុំចង់រៀនបន្តដល់សាកលវិទ្យាល័យ"

កញ្ញាអ៊ុន ចាន់ណា អាយុ១៧ឆ្នាំ មានស្រុកកំណើតនៅខេត្តតាកែវ ។ កញ្ញាជាកូនទី២ ក្នុងចំណោមបងប្អូនទាំងអស់ចំនួន ៤នាក់ ។

កញ្ញាបានរៀបរាប់ឱ្យដឹងថា : "ខ្ញុំបានធ្លាក់ខ្លួនពិការជើងទាំងពីរតាំងពីមានអាយុ ២ឆ្នាំមកម្ល៉េះ ។ កាលណោះ ខ្ញុំមានជំងឺគ្រុនក្តៅយ៉ាងខ្លាំងរហូតដល់សន្លប់បាត់ស្មារតី ។ ខ្ញុំក៏ត្រូវឪពុកម្តាយ នាំទៅមន្ទីរពេទ្យដើម្បីព្យាបាល ប៉ុន្តែជើងទាំងពីររបស់ខ្ញុំ ប្រែជាទន់រួមស្វិតទៅ ទើបបណ្តាលឱ្យខ្ញុំមិនអាចដើររួចចាប់ពីពេលនោះមក ។ កាលនៅស្រុកកំណើត ខ្ញុំធ្លាប់បានរៀនដល់ថ្នាក់ទី៣ដែរ ។ ប៉ុន្តែដោយពិបាក ក្នុងការធ្វើដំណើរទៅសាលារៀន ហើយនិងគួបផ្សំជីវភាពគ្រួសារមានការខ្វះខាតផង ខ្ញុំក៏ត្រូវបង្ខំចិត្តបញ្ឈប់ការសិក្សាទៅ ។ ក្រោយមកអង្គការម៉ារីស្សមិស្សិនជ្រើសរើសខ្ញុំឱ្យចូលរៀននៅសាលាឡាវ៉ាឡា" ។

កញ្ញាបានរៀបរាប់ថា កញ្ញាដែលបានចូលរៀននៅទីនេះ មានការរីកចម្រើនច្រើនជាងមុន ដោយនៅទីនេះ កម្មវិធីសិក្សាគឺមានការអប់រំទាំងចំណេះដឹងនិងសីលធម៌ផងដែរ ។ មនុស្សទាំងអស់នៅសាលាឡាវ៉ាឡានេះ មិនមានការរើសអើងចំពោះគ្នានោះឡើយ ពោលគឺទាំងគ្រូទាំងសិស្សម្នាក់ៗ មានស្ថានភាពពិការដូចគ្នា ។ ដូច្នេះយើងបង្ហាញនូវការយល់ចិត្តគ្នា រាប់អានគ្នា ព្រមទាំងយកចិត្តទុកដាក់ជួយធុរៈគ្នាទៅវិញទៅមកជានិច្ច ។



សម្រាប់ទៅថ្ងៃអនាគត កញ្ញាចាន់ណា មានបំណងចង់រៀនបន្តដើម្បីបង្កើនចំណេះដឹងបន្ថែមទៀត គឺរៀនរហូតដល់សកលវិទ្យាល័យ ។ ទោះបីជាកញ្ញាពិការជើងទាំងពីរក្តី ក៏កញ្ញានៅមានសេចក្តីសង្ឃឹម និងមាននូវគោលបំណងយ៉ាងខ្ពង់ខ្ពស់មួយសម្រាប់អនាគតរបស់ខ្លួនផងដែរ ។






ក្លឹបរាត្រី ! កន្លែងកំសាន្តដែលយុវវ័យត្រូវទប់អារម្មណ៍ខ្លួនឯង

hoto : S hylong

# ក្លឹបរាត្រី និងសង្គមរបស់យុវវ័យក្មេង

**ខាន់ ភីរម្យ**

ឈានមកដល់សតវត្សរ៍ទី២១ ដែលជាសម័យសកលភាវូបនីយកម្ម និងបច្ចេកវិទ្យាព័ត៌មានការរីកចម្រើន ក្លឹបរាត្រីបានត្រូវមនុស្សនៅសម័យនេះ ជាពិសេស យុវជនបានចាត់ទុកថា វាជាកន្លែងកំសាន្តមួយប្រភេទរបស់ពួកគេ ខណៈដែលចាស់ៗអភិរក្សអះអាងថា វាជាកន្លែងដែលភ្លើតភ្លើន ដែលនឹងនាំឱ្យយុវវ័យដើរផ្លូវខុស ។

អ្នកមីងសឿន សុផុល អាយុ៤៨ឆ្នាំ ជាប្រជាពលរដ្ឋក្នុងសហគមន៏មួយនៅខេត្តកំពង់ធំ មានប្រសាសន៍ថា គាត់ស្ទើរតែពុំហ៊ានអនុញ្ញាតឱ្យកូនគាត់មករៀននៅទីក្រុងភ្នំពេញ ដោយសារគាត់ល្បឺថា ភ្នំពេញគឺជាកន្លែងដែលសម្បូរទៅដោយកន្លែងកំសាន្តនានា ជាពិសេស គឺក្លឹបរាត្រីនេះតែម្តង ។ អ្នកមីងបានអះអាងថា : "ខ្ញុំតែងអប់រំកូនខ្ញុំ មិនឱ្យទៅកន្លែងដែលភ្លើតភ្លើនអ៊ីចឹងនោះទេ ខ្លាចកូនដើរផ្លូវខុស មិនគិតរៀនសូត្រ និងប៉ះពាល់ដល់អនាគត" ។

នេះគឺជាការយល់ឃើញមួយផ្លូវរបស់អ្នកមីងដែលគិតថា ក្លឹបរាត្រី ឬក៏កន្លែងកំសាន្តទាំងឡាយ ដែលមានស្ថានភាពបែបនេះអាចពង្វក់យុវជន និងយុវនារីក្មេងៗ ឱ្យដើរផ្លូវខុស ប៉ុន្តែសម្រាប់យុវជនទាន់សម័យមួយចំនួនវិញ គេហាក់ដូចជាមានយោបល់ផ្សេងពីអ្នកមីងទៅវិញ ។

បូរិទ្ធ អាយុ ២២ឆ្នាំ បានអះអាងយ៉ាងដូច្នេះនៅមុខក្លឹបរាត្រីមួយនៅក្រុងភ្នំពេញថា សម្រាប់ចាស់ៗ គឺគាត់ពិតជាយល់ថា ក្លឹប ឬកន្លែងរាំលេងនានា គឺជាកន្លែងដែលនាំឱ្យយើងដើរខុសផ្លូវ ប៉ុន្តែសូមកុំភ្លេចថា បរិយាកាសនានា នៅក្នុងបណ្តាទីកន្លែងកំសាន្តទាំងនោះ ជាបទពិសោធន៏ផ្នែកសង្គមមួយសម្រាប់យើង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏បូរិទ្ធមិនបានអះអាងថា អ្វីដែលចាស់ៗលោកគិតនោះ វាជាការខុសនោះដែរ ។ បូរិទ្ធ បានបញ្ជាក់ថា : "ពួកគាត់អះអាង (ចាស់ៗ) គឺត្រឹមត្រូវ ប៉ុន្តែពួកយើងក៏មិនខុសដែរ" ។ បូរិទ្ធដែលមើលទៅដូចជាយុវជនដែលនិយមភាពទំនើបតាមបែបសម័យនិយម លេងម៉ូតសក់ និងខោអាវ បាននិយាយថា ក្នុងនាមជាយុវជនម្នាក់ យើងត្រូវដឹងគ្រប់ផ្នែកនៃសង្គមទាំងអស់ តែទន្ទឹមនឹងនេះ យើងត្រូវចេះការពារខ្លួនយើង កុំឱ្យលង់ខ្លួនផងដែរ ។ បូរិទ្ធក៏បានបញ្ជាក់ដែរថា : "ខ្ញុំទៅដើម្បីកំសាន្ត និងដើម្បីកាត់បន្ថយភាពតានតឹងពីការរៀនសូត្រ តែយើងក៏ត្រូវប្រយ័ត្នដែរ ព្រោះនៅទីណាក៏មានអ្នកល្អ និងអាក្រក់ដែរ" ។

បូរិទ្ធ បានឱ្យដឹងថា ទីនោះអាចនឹងគ្រោះថ្នាក់បើរូបគេទៅទីនោះជាមួយនឹងមិត្តភក្តិ ដែលមិនស្គាល់ ពីប្រវត្តិ និងស្គាល់គ្រួសារច្បាស់លាស់ ។ តែបើយើងទៅជាមួយមិត្តល្អៗ គឺវាអាចជួយយើង ឱ្យចេះរួមសប្បាយ រួមទុក្ខជាមួយគ្នា មិនអីទេ ។ តែបើយើងចេះតែទៅផ្តេសផ្តាស វាអាចឱ្យយើងធ្លាក់ខ្លួនប្រើប្រាស់គ្រឿងញៀន និងឈ្លក់វង្វេងស្មារតីជាដើម ។

វ៉ានី (ឈ្មោះប្រឌិត) យុវនារីអាយុ ២០ឆ្នាំ កំពុងតែសិក្សានៅសកវិទ្យាល័យធនធានមនុស្ស ក៏និយាយថា រូបកញ្ញាមិនដែលបានទៅក្លឹបរាត្រី ឬកន្លែងដើរលេងយប់នោះទេ ។ ប៉ុន្តែក្នុងនាមជាយុវវ័យ មួយរូប កញ្ញាក៏ចង់ស្គាល់ទីនោះដែរ ។

វានីបញ្ជាក់ថា : "ខ្លះគេក៏ថា ទៅទីនោះល្អ ខ្លះទៀតគេថា ទីនោះអាក្រក់ ប៉ុន្តែខ្ញុំមិនទាន់បានឃើញនឹងភ្នែក ។ ខ្ញុំចង់ស្គាល់ម្តងដើម្បីវិភាគខ្លួនឯង" ។

វ៉ានីក៏បានឱ្យដឹងថា បទពិសោធន៏ដែលនាងចង់បាននេះអាចជាបទពិសោធន៏ជីវិតដ៏ល្អមួយ ព្រោះកញ្ញាអាចនឹងជួបនៅក្នុងពេលអនាគត ។ ដូច្នេះបើសិនជាដឹងមុន រូបកញ្ញាអាចរកឃើញវិធីសាស្ត្រដើម្បីដោះស្រាយបាន ។ ប៉ុន្តែបើមិនដឹងសោះនោះ គឺវាលំបាកដែរនៅក្នុងការតបត ។

December-2008.qxd 11/27/2008 6:09 PM Page 10

## បទយកការណ៍

# កម្មករជំនាញ អាជីពមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍន៍

**ខាន់ ភីរម្យ**

ក្នុងសម្លៀកបំពាក់ជាឯកសណ្ឋានពណ៌ខៀវ ពួកគេបានបែកចែកគ្នាជាក្រុមៗនៅតាមបន្ទប់។ នៅក្នុងបន្ទប់មួយ មានសិស្សខ្លះកាន់ដែក និងអ្នកខ្លះទៀតកាន់ខ្សែភ្លើង។ នៅបន្ទប់មួយផ្សេងទៀតនោះ មានសិស្សខ្លះកាន់ម៉ាស៊ីនជាដើម។ ហើយភាគច្រើនមុខមាត់របស់ពួកគេ គឺមានប្រឡាក់ប្រេងបន្តិចបន្តួច។ បរិយាកាសនៅទីនោះពោរពេញទៅដោយសំឡេងទ្រហឹងជួនកាលធ្ងន់ និងជួនកាលស្រាល។ ទាំងនេះគឺជាទិដ្ឋភាព ដែលគេអាចពិពណ៌នា នៅក្នុងអគារមួយនៃសាលាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈមួយកន្លែង ដែលឋិតនៅជាយក្រុងភ្នំពេញ។ សាលានេះហៅថាសាលាបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូ ដែលកំពុងតែផ្តល់ចំណេះវិជ្ជាដើម្បីចិញ្ចឹមជីវិតដល់យុវជន និងយុវនារី មានសរុបប្រមាណ ៥២៦នាក់ លើផ្នែកកម្មករជំនាញ និងឯកទេស។ មុខជំនាញដែលនិស្សិតម្នាក់ៗ រៀននៅទីនោះ គឺមានរយៈពេល ២ឆ្នាំ។ នៅពេលដែលពួកគេបញ្ចប់ការសិក្សាហើយ ពួកគេនឹងក្លាយទៅជាកម្លាំងស្នូលដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍ ប្រទេសកម្ពុជា ទន្ទឹមនឹងពេលដែលយុវជន យុវនារីមួយចំនួន ហាក់ដូចជាមិនយកចិត្តទុកដាក់លើជំនាញ និងឯកទេសនោះឡើយ។

លោកស៊ុយ ឆេង នាយកសាលាដុនបូស្កូភ្នំពេញបានមានប្រសាសន៍ថា មុខវិជ្ជាទាំងអស់ដែលយើងមានបង្រៀននៅទីនេះ គឺជាមុខជំនាញដែលយុវជនខ្មែរមួយចំនួនមិនសូវចាប់អារម្មណ៍ដោយសារនៅពេលដែលបញ្ចប់ការសិក្សាទៅ ពួកគេត្រូវចាប់ផ្តើម ធ្វើជាមួយនឹងការងារមួយបែប ដែលបែកញើស និងប្រឡាក់ប្រឡូស ខុសប្លែកពីមុខជំនាញផ្សេងទៀតដែលបណ្តុះបណ្តាលដោយស្ថាប័នឧត្តមសិក្សានានានៅក្នុងប្រទេស ដែលភាគច្រើន គឺនិស្សិតចេញទៅត្រូវធ្វើការនៅក្នុងការិយាល័យនោះ។



hoto : L. Samphors

សិក្សាដោយផ្សារភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តន៍

### សាលាបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូ

**សាលាបច្ចេកទេសដុនបូស្កូភ្នំពេញ គឺជាសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមួយ ដែលបានបង្កើតឡើងនៅប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៩១ ក្រោមការឧបត្ថម្ភដោយមូលនិធិដុនបូស្កូកម្ពុជា។**

**លោកស៊ុយ ឆេង នាយកសាលាដុនបូស្កូភ្នំពេញ មានប្រសាសន៍ថា រហូតមកដល់បច្ចុប្បន្ននេះ សាលាបានបណ្តុះបណ្តាលយុវជនប្រមាណ ៣០០០នាក់ លើមុខវិជ្ជាសំខាន់ៗ ៥ គឺជាងក្រឡឹង និងផ្សារ អគ្គិសនី បោះពុម្ព អេឡិចត្រូនិច និងគ្រឿងយន្ត។ កម្មវិធីសិក្សាមានរយៈពេល ២ឆ្នាំ។ បច្ចុប្បន្ននេះ សាលាកំពុងបណ្តុះបណ្តាលយុវជនក្រីក្រ សរុប៥២៦នាក់ គឺ ឆ្នាំទី១ មាននិស្សិត ២២០នាក់ ចម្រាញ់ជ្រើសរើសពីបេក្ខជនប្រឡង ១២២៤នាក់។ ឆ្នាំទី២ មាននិស្សិតចំនួន ៣០៦នាក់។ សាលាដុនបូស្កូមាន ៥សាខា គឺនៅភ្នំពេញ ក្រុងកែប ខេត្តបាត់ដំបង ទីប្រជុំជនប៉ោយប៉ែត និងក្រុងព្រះសីហនុ។**

នៅក្នុងចំណោមយុវជនទាំងអស់ មឿន លីឃុន ជាយុវជនម្នាក់ ដែលសម្រេចចិត្តចូលសិក្សាផ្នែកកម្មករជំនាញខុសប្លែកពីយុវជនចំនួន ១៣៥០០០នាក់ ដែលបានចុះឈ្មោះចូលរៀន នៅឯថ្នាក់ឧត្តមសិក្សានៅក្នុងប្រទេសសម្រាប់ឆ្នាំ២០០៧-២០០៨នេះ។ លីឃុនក៏ជាយុវជនម្នាក់ ដែលបានចាកចេញពីស្រុកកំណើតនៅខេត្តកំពង់ចាម ហើយមកបន្តការសិក្សានៅទីក្រុងភ្នំពេញដោយចាប់យកជំនាញក្រឡឹង។ ចំណែកមូលហេតុដែលធ្វើឱ្យលីឃុនសម្រេចជ្រើសរើសជំនាញនេះ គឺដោយសារតែភាពក្រីក្រនិងកង្វះខាតសមត្ថភាពដើម្បីប្រឡងយកអាហារូបករណ៍ចូលរៀននៅថ្នាក់ឧត្តមសិក្សាទាំងឡាយនៅទីក្រុងភ្នំពេញ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ លោកនៅពុះពាររហូតដល់អាចប្រឡងជាប់នៅសាលាបណ្តុះបណ្តាល វិជ្ជាជីវៈដុនបូស្កូនឹងគេ។ សម្រាប់លីឃុនមុខអាជីពជាកម្មករជំនាញ និងមានឯកទេសនេះគឺជាទុនមួយ។ លោកគិតថា លោកអាចនឹងស្វែងរកការងារបានធ្វើ នៅពេលដែលលោកបញ្ចប់នូវការសិក្សាលើផ្នែកនេះដែរ។ លីឃុន ក៏បានអះអាងថា គិតទៅ នៅពេលដែលលោកបានចាកចេញពីស្រុកកំពង់សៀម ខេត្តកំពង់ចាម ដែលជាស្រុកកំណើត លោកក៏មានគោលបំណងចង់រៀននៅមហាវិទ្យាល័យនឹងគេដែរ។ តែរូបលោកពុំអាចមានលទ្ធភាពគ្រប់គ្រាន់ទេ។ ដូច្នេះលោកសម្រេចចិត្តដាក់ពាក្យចូលប្រឡង នៅសាលាដុនបូស្កូរហូតបានជាប់ និងបានរៀនជាមួយនឹងគេរបស់មកទល់នឹងសព្វថ្ងៃ។ លោកបានបន្តដែរថា លោកក៏ចង់រៀននៅសាលាល្អ ចង់ស្លៀកពាក់ស្អាតបាត មិនប្រឡាក់ប្រឡូស និងមានការងារធ្វើល្អនឹងគេដែរ។ ប៉ុន្តែទោះបីជាយ៉ាងណា សព្វថ្ងៃនេះ លោកមិនមានតូចចិត្តដែរ ហើយលោករំពឹងថា នៅពេលរៀនចប់ លោកក៏នឹងអាចយកមុខជំនាញវិជ្ជាជីវៈដែលបានរៀន ដើម្បីស្វែងរកការងារធ្វើសម្រាប់ចិញ្ចឹមគ្រួសារ និងខ្លួនឯងបាននឹងគេដែរ។ លីឃុន បានគូសបញ្ជាក់ថា: "គេរៀនសាលាល្អ។ គេអាចរកការងារធ្វើបាន។ ប៉ុន្តែខ្ញុំមិនដែលអស់សង្ឃឹមឡើយ។ ខ្ញុំតែងរំពឹងថា ខ្ញុំអាចរកការងារធ្វើបានដូចគេដែរ"។

ចំណែកយុវជនយ៉ែម វី វិញ មានអាយុ២១ឆ្នាំ និងមកពីស្រុកបសេដ្ឋខេត្តកំពង់ស្ពឺ។ លោកបានឱ្យដឹងថា លោកជាកូនទី៤ នៅក្នុងចំណោមបងប្អូនបង្កើត ៨នាក់។ លោកបញ្ចប់ការសិក្សាបាននៅត្រឹមថ្នាក់ទី១២ ដោយមិនបានជាប់សញ្ញាបត្រទុតិយភូមិនឹងគេ ឡើយដោយសារលោកខ្វះធនធាន នៅក្នុងការសិក្សាឱ្យបានគ្រប់គ្រាន់ដូចគេ។ ប៉ុន្តែលោកក៏អាចមានឱកាសទទួលនូវជោគជ័យសម្រាប់ការប្រឡងជាប់ចូលរៀននៅសាលាដុនបូស្កូភ្នំពេញជាមួយនឹងមុខវិជ្ជាអគ្គិសនី។ យ៉ែម វី ក៏បានបញ្ជាក់ថា: "មុខជំនាញនេះ គឺជាស្ពានតែមួយគត់របស់លោក ដើម្បីចាប់យកឱកាសការងារធ្វើ"។

រហូតមកទល់នឹងសព្វថ្ងៃនេះ ការអភិវឌ្ឍន៍ធនធានមនុស្សគឺជាគោលនយោបាយមួយដែលរដ្ឋាភិបាលកម្ពុជា បានកំពុងតែយកចិត្តទុកដាក់ជាអាទិភាព។ ជាក់ស្តែង នាពេលបច្ចុប្បន្ននេះ ក្រសួងអប់រំយុវជន និងកីឡា ក៏បានយល់ព្រមឱ្យមានការបង្កើតស្ថាប័នឧត្តមសិក្សារហូតទៅដល់ ប្រមាណជា ៧០ស្ថាប័ន ហើយក៏មាននិស្សិតកំពុងចុះឈ្មោះចូលរៀនរហូតដល់ទៅ ១៣៥០០០នាក់ សម្រាប់ឆ្នាំសិក្សា ២០-០៧-២០០៨នេះ។ តែបញ្ហាប្រឈមដែលគេកំពុងព្រួយបារម្ភនោះ គឺថា តើពួកគេនឹងធ្វើអ្វី នៅពេលដែលគេបញ្ចប់ការសិក្សានោះ។ ហើយក្រៅពីចំនួននេះចេញ ក៏មានយុវជនខ្លះកំពុងតែសិក្សានៅតាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញផ្សេងៗ គឺមានដូចជាលីឃុន និងយ៉ែម វី ដែរ។

លោកស៊ុយ ឆេង បានមានប្រសាសន៍ដែរថា កម្មករជំនាញឯកទេស ពុំមែនជាអាជីពការងារដែលមានការរើសអើងនោះទេ។ វាជាស្ពានឆ្លងមួយដ៏សំខាន់ឆ្ពោះទៅរកភាពជោគជ័យ នាពេលអនាគតនៅក្នុងអាជីពការងារដែរ។ យុវជនៗទាំងអស់គួរមានការចាប់អារម្មណ៍ទៅនឹងបច្ចេកទេសទាំងនេះ។ លោកបានបញ្ជាក់ថា: "បើម្នាក់ៗគឺសុទ្ធតែចង់ធ្វើការងារនៅការិយាល័យ មានម៉ាស៊ីនត្រជាក់ ហើយបំភ្លេចការងារជាកម្មករជំនាញនៅតាមរោងជាង ដែលជាប្រភេទការងារបែកញើស នោះសេដ្ឋកិច្ចសង្គមនិងការអភិវឌ្ឍន៍នឹងឈានទៅមុខមិនរួចទេ"។ លោកបានឱ្យដឹងដែរថា នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ កម្មករជំនាញ គឺអាចមានឱកាសទទួលបានការងារច្រើនជាងការងារនៅការិយាល័យផង ហើយប្រាក់ខែវិញ ក៏មានគ្រាន់បើដែរ។ ទីផ្សារការងារលើមុខជំនាញនៅមានភាពទូលំទូលាយច្រើន។ លោកបានបញ្ជាក់ដែរថា: "និស្សិតដែលបញ្ចប់ការសិក្សានៅសាលាដុនបូស្កូ ស្ទើរតែ១០០% ទទួលបានការងារធ្វើ។ សម្រាប់ក្រុមហ៊ុននានា គឺគេមកកក់បុគ្គលិកតាំងតែពីសិស្សរៀនមិនទាន់ចប់ម្ល៉េះ ហើយពួកគេក៏អាចមានសមត្ថភាព ទទួលប្រាក់បៀវត្សរ៍ពី ៨០ ដុល្លារ ទៅ៦០០ ដុល្លារ ហើយមានអ្នកខ្លះអាចបានខ្ពស់ជាងនេះថែមទៀតផង"។

**បច្ចេកទេសនៅក្នុងការស្វែងរកការងារធ្វើ**

**"នៅក្នុងខណៈពេលដែលទីផ្សារការងារកាន់តែចង្អៀតឡើងៗ ដើម្បីទទួលបានការងារធ្វើ យុវជនម្នាក់ៗ ត្រូវតែមានគុណភាព និងសមត្ថភាពដោយខ្លួនឯងខាងចំណេះដឹង"។ នេះបើតាមការអះអាងរបស់លោកស្រីម៉ៅ ពុទ្ធារ័ត្ន ដែលជាអ្នកសម្របសម្រួលនៃក្រុមប្រឹក្សាយុវជនកម្ពុជា។**

**លោកស្រី មានប្រសាសន៍ថា គុណភាព និងសមត្ថភាព គឺជាចំណុចគន្លឹះនៅក្នុងទីផ្សារការងារ ប៉ុន្តែទន្ទឹមនឹងនោះ យុវជនម្នាក់ៗ ក៏គួរតែចេះជ្រើសរើសនូវមុខវិជ្ជាណាដែលសង្គមនៅខ្វះខាត ហើយកុំគិតតែស្វែងរកការងារណាដែលចំនឹងជំនាញខ្លួនឯងពេក។ លោកស្រីបន្តទៀតថា: "បើយើងរៀនគណនេយ្យ កុំគិតតែរកការងារផ្នែកគណនេយ្យនោះ ការងារណាក៏ដោយ ឱ្យតែអាចធ្វើបាន គឺត្រូវតែធ្វើ ដើម្បីជាការបើកឱកាសខ្លួនយើង និងទទួលបានបទពិសោធន៍ថ្មីៗ"។ លោកស្រីបន្ថែមថា នៅពេលរៀន និស្សិតម្នាក់ៗ គួរតែឆ្លៀតពេលរៀនហ្វឹកហ្វាត់ធ្វើការងារ តាមរយៈការសុំហាត់ការនៅតាមកន្លែងផ្សេងៗ ដើម្បីឱ្យយើងយល់អំពីការសិក្សា និងការងាររបស់យើង។**

ពាក់ព័ន្ធជាមួយបញ្ហាទីផ្សារការងារ សម្រាប់យុវជន នៅក្នុងប្រទេសកម្ពុជា អ្នកជំនាញការដែលធ្វើការជិតស្និទ្ធនឹងយុវជន បានអះអាងថា យុវជនជាច្រើនកំពុងតែប្រឈមមុខនឹង បញ្ហាអត់ការងារធ្វើនៅពេលដែលពួកគេបញ្ចប់ការសិក្សា ។

លោកស្រីម៉ៅ ពុទ្ធារ័ត្ន អ្នកសម្របសម្រួលនៃក្រុមប្រឹក្សានៃយុវជនកម្ពុជាបានមានប្រសាសន៍ថា នៅក្នុងពេលនេះ ទីផ្សារការងារសម្រាប់យុវជនកម្ពុជាមានលក្ខណៈចង្អៀតណាស់។ ចំណែកចំនួននិស្សិតដែលចេញពីសកលវិទ្យាល័យនានានៅក្នុងប្រទេសនាពេលនេះ ក៏មិនមានតុល្យភាពនឹងទីផ្សារការងារឡើយ។ លោកស្រី បានបញ្ជាក់ថា: "ជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាត្រូវតែប្រឹងប្រែងបង្កើតការងារថ្មីៗ សម្រាប់យុវជន យុវនារី មានប្រមាណពី ៣០០០០០នាក់ ទៅ៤០០០០០នាក់ ដែលចេញពីគ្រឹះស្ថានសិក្សានានា។ តែជាអកុសល បើតាមរបាយការណ៍ដែលគេធ្លាប់ធ្វើការសិក្សា នាពេលកន្លងមកបានបង្ហាញថា ក្នុងចំណោមយុវជន ១០នាក់ គឺមានម្នាក់ប៉ុណ្ណោះដែលអាចរកការងារធ្វើបាន"។

December-2008.qxd 11/27/2008 6:09 PM Page 12

## កសិកម្ម

# ជន្លេន អាចក្លាយជាប្រភពចំណូល

**ខាន់ ភីរម្យ**

ជន្លេនដែលគេអាចឃើញនៅស្ទើរតែពាសពេញដីជាពិសេសនៅតាមស្រុកស្រែចំការនោះ ក៏អាចឱ្យគេអភិវឌ្ឍយកវាទៅចិញ្ចឹមបានដែរ ដើម្បីបំពេញតម្រូវការនៅក្នុងកសិដ្ឋានចិញ្ចឹមត្រីបាន ព្រោះពួកវាមានប្រូតេអ៊ីនយ៉ាងសម្បូរសម្រាប់ត្រីស៊ី ។


hoto : L. Samphors

លោករាជ ធាន កសិករវ័យ ៦៤ឆ្នាំ ម្ចាស់កសិដ្ឋានចិញ្ចឹមត្រី និងកង្កែបមួយកន្លែង នៅក្នុងខេត្តស្វាយរៀង អះអាងថា នៅពេលនេះជន្លេន ១គីឡូក្រាមអាចលក់បានតម្លៃប្រមាណ ៥000រៀល ។ ជន្លេនទាំងនោះគឺត្រូវបានលក់ដើម្បីយកទៅផ្គត់ផ្គង់តាមកសិដ្ឋានចិញ្ចឹមត្រីនានា ។

លោកពូបានមានប្រសាសន៍ថា: "ជន្លេនគឺជាប្រភពចំណើរបស់ត្រីមួយ ដ៏សំខាន់ ។ ដូច្នេះនៅពេលដែលមានកន្លែងចិញ្ចឹមត្រីច្រើននោះ ជន្លេនក៏អាចក្លាយទៅជាមុខរបរមួយបានដែរ" ។

លោករាជ ធាន បានបន្តទៀតដែរថា ដោយសារតែតម្លៃជន្លេនតាមទីផ្សារឡើងទៅដល់ ៥000រៀលក្នុងមួយគីឡូក្រាមនោះ លោកក៏បានបើកជាកន្លែងចិញ្ចឹមជន្លេនមួយឡើងដើម្បីផ្គត់ផ្គង់ត្រី និងកង្កែបរបស់លោកផ្ទាល់ ហើយក៏ដើម្បីលក់ដែរ ប្រសិនបើមានអតិថិជនគេត្រូវការទិញនោះ ។ លោកបានបន្តទៀតថា សម្រាប់ការចិញ្ចឹមជន្លេននេះ វាមិនសូវជាពិបាកទេ ។ ដើម្បីចិញ្ចឹមពួកវាបាន គឺត្រូវតែរៀបចំកន្លែងមួយឱ្យបានត្រឹមត្រូវ គឺដូចជាចាក់ស៊ីម៉ង់នៅកន្លែងចិញ្ចឹម ដើម្បីការពារកុំឱ្យជន្លេនត្បុលចេញពីកន្លែងចិញ្ចឹម រៀបចំទឹកព័ទ្ធជុំវិញនៅកន្លែងចិញ្ចឹមដើម្បីការពារស្រមោចកុំឱ្យចូលស៊ីជន្លេនហើយត្រូវរៀបចំដីដាក់លាយជាមួយនឹងអាចម៍គោស្រស់ ជាប្រចាំ ពីព្រោះជន្លេនវាចូលចិត្តស៊ីអាចគោស្រស់ជាចំណី ហើយដាក់ជន្លេនចូលទៅជាការស្រេច ។ ប៉ុន្តែក៏ត្រូវមើលថែ និងត្រូវស្រោចទឹកឱ្យសើមជាប្រចាំដែរ ទើបវាបានទទួលផលល្អ ។

សព្វថ្ងៃនេះ លោករាជ ធាន មានស្រះបង្កាត់ពូជត្រី និងអាចចិញ្ចឹមកង្កែប ប្រមាណជា ៣0 និងកន្លែងចិញ្ចឹមជន្លេនមួយដែលមានទំហំ ៨ម៉ែត្រការ៉េដែលអាចផ្តល់ផលគ្រប់គ្រាន់សម្រាប់ឱ្យគាត់យកធ្វើជាចំណីត្រីនិងកង្កែបរបស់គាត់បាន ។ បន្ថែមពីលើនេះគាត់អាចដោះដូរយកប្រាក់ចំណូលបន្ថែមសម្រាប់សេដ្ឋកិច្ចគ្រួសាររបស់គាត់បាន ។

លោកក៏បានបញ្ជាក់ថា: "ជន្លេនរបស់គាត់មិនមែនលក់តែជន្លេនសុទ្ធ ទើបបានមួយគីឡូ ៥000រៀលនោះទេ គឺលក់ទាំងដី និងទាំងជន្លេន" ។

## បរិស្ថាន

# បញ្ហាវារីអគ្គីសនី

គម្រោងវារីអគ្គីសនីនៅកម្ពុជា ចេះតែដំណើរការទៅមុខ ។ ប៉ុន្តែបើតាមអ្នកជំនាញបរិស្ថាន បានឱ្យដឹងថា វារីអគ្គីសនីគឺជាការអភិវឌ្ឍន៍មុខពីរ ។


hoto : D

បញ្ហានេះត្រូវបានលើកឡើងក្នុងសន្និសីទកាសែតមួយនៅក្នុងវេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា អំពីគម្រោងអភិវឌ្ឍន៍វារីអគ្គីសនី ហៅថាគីរីរម្យ៣ ដែលនឹងសាងសង់ឆាប់ៗខាងមុខនេះ ។

លោកងី សន នាយកប្រតិបត្តិរងនៃវេទិកាអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជាបានមានប្រសាសន៍ថា: "គម្រោងវិនិយោគវារីអគ្គីសនី គឺអាចផ្តល់អគ្គីសនីដែលកម្ពុជាកំពុងតែខ្វះ តែវាឱ្យផលប៉ះពាល់ដល់ធម្មជាតិ និងសហគមន៍" ។

លោកក៏ប្រាប់ថា បច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាដែលអាចប្រើអគ្គីសនី គឺមានចំនួនត្រឹមតែ ២0% ប៉ុណ្ណោះ ។ នៅឆ្នាំ២0៣0ខាងមុខ រដ្ឋាភិបាលមានគោលដៅផ្តល់ភ្លើងដល់ប្រជាពលរដ្ឋប្រើប្រាស់ឱ្យបាន ៧0% ។ ដូច្នេះគម្រោងអភិវឌ្ឍន៍វារីអគ្គីសនីគឺជាសក្តានុពលមួយ ។ ប៉ុន្តែគម្រោងទាំងនេះអាចនឹងមានផលប៉ះពាល់ផ្នែកបរិស្ថានផ្សេងៗ ដូចជាបាក់ដីនៅតាមដងស្ទឹង ទន្លេ ឬព្រៃ ការជន់លិចការប្រែប្រួលនូវរបបទឹកហូរ ការខូចគុណភាពទឹកការបាត់បង់ជម្រកសត្វព្រៃ និងធ្វើឱ្យប៉ះពាល់ដល់ជីវសាស្ត្រចម្រុះជាដើម ។

លោកបានសង្កត់ធ្ងន់ថា ដើម្បីជំរុញផែនការអភិ-វឌ្ឍន៍វារីអគ្គីសនីនេះទទួលបាននូវជោគជ័យនោះគម្រោងវិនិយោគទាំងឡាយគួរតែមានការសិក្សាអំពីផលប៉ះពាល់មុនដូចជាការដោះស្រាយសំណងឱ្យអ្នកទទួលការប៉ះពាល់ និងការកសាងទំនប់ឱ្យមានស្តង់ដារត្រឹមត្រូវជាដើម ។



## សុខភាព

# បញ្ហារាំងរដូវ ទោះមិនសូវគ្រោះថ្នាក់ ប៉ុន្តែក៏ត្រូវតែព្យាបាល

**អាតន**

ចុកចាប់រាងកាយត្រង់ចង្កេះ សន្លាក់ជើងសន្លាក់ដៃ ហេវហត់អស់កម្លាំង ចុកពោះ ទាំងនេះជាអាការៈសម្រាប់នារី ដែលកើតមានឡើងដោយសារតែការធ្លាក់រដូវ ឬក៏រាំងរដូវ ។

លោកវេជ្ជបណ្ឌិតស៊ឹម សូផៃ អ្នកឯកទេសខាងជំងឺកាមរោគ សើស្បែក និងរោគស្ត្រី ក៏មានប្រសាសន៍ថា អាការៈខាងលើ ជាអាការៈដែលអាចកើតមានចំពោះស្ត្រីគ្រប់ៗគ្នា នៅក្នុងវ័យបន្តពូជ ។

លោកបញ្ជាក់ផងដែរថា: "ចំពោះការធ្លាក់រដូវនេះបើវាមកមួយខែម្តងសម្រាប់នារី នោះគឺវាមិនមែនជាជំងឺទេ វាគឺជាធម្មជាតិ ប៉ុន្តែប្រសិនជាខែណាមិនមានធ្លាក់ នោះទើបជាបញ្ហា" ។

លោកបន្តទៀតដែរថា ជាទូទៅសម្រាប់នារី ដែលមានជំងឺនេះគឺមានពីរប្រភេទធំៗ ។ ទីមួយ ប្រសិនបើនារីមិនមានរដូវ ចាប់ពីពេញវ័យរហូតដល់អាយុ ២៥ឆ្នាំ មិនដែលមានសោះ គេចាត់ទុកថា គឺជាជំងឺរាំងរដូវនៅដំណាក់កាលដំបូង ហើយប្រសិនជានារីនោះ គាត់ធ្លាប់មានរដូវ តែស្រាប់តែបាត់ ឬក៏ខែខ្លះធ្លាក់ ហើយខែខ្លះទៀត មិនធ្លាក់នោះ គឺគេហៅថាជាជំងឺរាំងរដូវដំណាក់កាលទីពីរ ។ សម្រាប់ប្រភេទទីពីរ ការរាំងរដូវនេះ គេអាចចាត់ទុកថា ជាធម្មតានៅពេលដែលអ្នកជំងឺចាប់ផ្តើមមានគភ៌ តែបើគ្មានទេ វាគឺជាជំងឺរាំងរដូវហើយ ។

លោកបានបន្តទៀតថា អ្នកជំងឺប្រភេទទាំងពីរនេះមិនមែនជាជំងឺធ្ងន់ធ្ងរទេ ប៉ុន្តែអ្នកជំងឺត្រូវព្យាបាលជាបន្ទាន់ជាមួយនឹងគ្រូពេទ្យដែលមានជំនាញត្រឹមត្រូវផងដែរ ។ បើពុំដូច្នេះទេ វាអាចទៅជាជំងឺមួយផ្សេងទៀត ។ ហើយសម្រាប់ផលលំបាកដែលកើតមានចំពោះនារីដែលមានបញ្ហានេះ គឺថា គាត់មានរាងកាយស្គមស្គាំង ស្លេកស្លាំង និងរសេះរសោះជាដើម ។ ចំណែកមូលហេតុដែលនាំឱ្យកើតជាជំងឺនេះបានគឺដោយសារតែមានបញ្ហាលើអ័រម៉ូន មកពីការវះកាត់ ឬក៏មានបញ្ហាកន្សោមពង ។


hoto : L. Samphors

លោកវេជ្ជបណ្ឌិតស៊ឹម សូផៃ ក៏បន្តថា ការព្យាបាលជំងឺនេះ មានច្រើនវិធីដែរដោយរាប់ចាប់ពីលំហាត់ប្រាណឡើងទៅ រហូតដល់ការប្រើប្រាស់ថ្នាំ ។ ប៉ុន្តែទោះជាយ៉ាងណាក្តី រាល់ការប្រើប្រាស់ថ្នាំទាំងអស់អ្នកជំងឺដាច់ខាតត្រូវតែជួបជាមួយគ្រូពេទ្យជំនាញ ដោយគាត់មិនគួរប្រើប្រាស់ថ្នាំតាមតែការព្ធតគ្នានោះទេព្រោះប្រភេទជំងឺខុសគ្នា ហើយវិធីព្យាបាលក៏ខុសគ្នាដែរ មានតែគ្រូពេទ្យទេ ដែលអាចកំណត់និងព្យាបាលតាមរោគសញ្ញាបាន ។

### អាហារទាន់ចិត្តធ្វើឱ្យក្មេងធាត់លើសទម្ងន់

តាមសារព័ត៌មានវ៉យទ័របានឱ្យដឹងថា អាម៉េរិកកំពុងតែហាមឃាត់ការផ្សាយពាណិជ្ជកម្មអំពីអាហារទាន់ចិត្តតាមទូរទស្សន៍ ដោយសារតែខ្លាចកុមារកាន់តែច្រើនប្រឈមមុខនឹងជំងឺធាត់។ ការហាមឃាត់របស់ទីក្រុងវ៉ាស៊ីនតោន នឹងអាចកាត់បន្ថយចំនួនកុមារដែលប្រឈមមុខនឹងជំងឺលើសទម្ងន់ប្រមាណ ១៨%។

មជ្ឈមណ្ឌលបង្ការ និងត្រួតពិនិត្យជំងឺរបស់អាម៉េរិក បានឱ្យដឹងថា នៅក្នុងចំណោមកុមារដែលមានអាយុពី២ ទៅ៥ឆ្នាំ កុមារដែលប្រឈមមុខនឹងជំងឺលើសទម្ងន់មានរហូតដល់ទៅ១៣,៩% ដោយឡែកសម្រាប់កុមារពីអាយុ៦ឆ្នាំ ទៅដល់អាយុ១១ឆ្នាំវិញ គឺមានរហូតដល់ទៅ ១៨,៨%ឯណោះ។ ជាមួយនឹងតួលេខនេះមជ្ឈមណ្ឌលបានព្រមានថា ភាគរយបានកំពុងតែកើនឡើងគួរឱ្យកត់សម្គាល់។ ចំណែកឯទូរទស្សន៍ក៏មានតួនាទីខ្លាំងណាស់ដែរចំពោះការជំរុញឱ្យមានការកើនឡើងនេះ។

# រលាកផ្លូវដង្ហើមចំពោះកុមារ


hoto : . Samphy

បើតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិតហែម សុខហាននៃមន្ទីរពេទ្យកុមារជាតិបានឱ្យដឹងថា:

ជំងឺរលាកផ្លូវដង្ហើមអាចជាជំងឺដែលកើតឡើងលើផ្នែកនានារបស់ផ្លូវដង្ហើម រាប់តាំងពីច្រមុះ បំពង់កបំពង់ខ្យល់ ផ្លូវចេញចូលសួត ឬសួត ។ ជំងឺរលាកផ្លូវដង្ហើមនេះ ច្រើនបង្កឡើងដោយពពួកវីរុស និងពួកបាក់តេរី ។ មូលហេតុចម្បងនៃការឆ្លង គឺតាមរយៈការកណ្តាស់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងការរស់នៅក្នុងបរិស្ថានបរិយាកាសអាប់អួរ ហើយមានមនុស្សកកកុញ និងធូលីដីហុយច្រើនជាដើម ។

ការវិវត្តន៍របស់ជំងឺរលាកផ្លូវដង្ហើម មានបីដំណាក់កាលសំខាន់ៗ ។ ទីមួយ គឺការក្អក និងផ្តាសាយ ។ ទីពីរ គឺរលាកសួត និងទីបី គឺរលាកសួតធ្ងន់ធ្ងរ ។

សម្រាប់ការក្អក និងផ្តាយសាយ គឺកុមារក្អក ហៀរសំបោរ តឹងច្រមុះ និងក្តៅខ្លួន-ល- ហើយនេះអាចជារោគសញ្ញារបស់ជំងឺរបេង ហឺត ជំងឺក្អកមាន់ ឬក៏បញ្ហាដទៃៗទៀត ។ សម្រាប់ការរលាកសួត កាលណាកុមារមានក្អក ឬពិបាកដកដង្ហើម រួមនិងរោគសញ្ញាមួយចំនួនទៀត ដូចជាកុមារថ្ងូរ និងផ្ទាំងទ្រូងនាផ្នែកខាងក្រោមផតចូលពេលកុមារដកដង្ហើម ។ ទីបី រលាកសួតធ្ងន់ធ្ងរ កុមារឡើងស្វាយបបូរមាត់ បៅមិនបាន ផឹកក៏មិនបាន ក្អួត និងដកដង្ហើមញាប់ខ្លាំង ហើយកុមារឡើងប្រកាច់សន្លប់ មិនដឹងខ្លួន ។ ដំណាក់កាលនេះ កុមារស្ទើរតែជួយសង្គ្រោះ លែងបានដោយសារសរីរាង្គគេខ្វះអុកស៊ីសែនខ្លាំង ។

ជាចុងក្រោយ លោកវេជ្ជបណ្ឌិត បានសំណូមពរថា ឪពុកម្តាយទាំងឡាយ នៅពេលឃើញកូនមានក្អកច្រើន និងពិបាកដកដង្ហើមនោះ សូមយកគេទៅរកសេវាសុខភាពជាមួយវេជ្ជបណ្ឌិតជំនាញជាបន្ទាន់ ដើម្បីទទួលការព្យាបាលឱ្យទាន់ពេល ហើយជៀសវាងការផ្សំថ្នាំលេបខ្លួនឯងផ្តេសផ្តាស ។

**ផាត សំភី**

December-2008.qxd 11/27/2008 6:09 PM Page 14

# សិល្បៈ


hoto : D
រូបភាពមួយក្នុងចំណោមរូបភាពជាច្រើនដែលយកមកតាំងពិព័រណ៍

# មហោស្រពរូបថតរៀបចំនៅចុងខែវិច្ឆិកា និងដើមខែធ្នូ

**ខាន់ ភីរម្យ**

មហោស្រពពិព័រណ៍ខាងរូបថតចម្រុះជាតិសាសន៍មួយនឹងត្រូវរៀបចំឡើងនៅទីក្រុងសៀមរាប និងក្រុងភ្នំពេញនៅចុងខែវិច្ឆិកា និងដើម ខែធ្នូ ចុងឆ្នាំ២០០៨នេះ ដើម្បីជាពាំនាំយកមកនូវគំរូសិល្បៈថ្មីមួយបែបមកកាន់ប្រទេសកម្ពុជា។

លោកកោ បូរិន មន្ត្រីផ្នែកវប្បធម៌នៃមជ្ឈ-មណ្ឌលវប្បធម៌បារាំង នៅកម្ពុជា បានមានប្រសាសន៍ឱ្យដឹងថា មហោស្រពរូបថតនេះនឹងត្រូវរៀបចំនៅពីរកន្លែង គឺទីមួយ នៅទីក្រុងសៀមរាប ដែលជាទីក្រុងទេសចរណ៍របស់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ហើយមួយទៀតធ្វើនៅក្នុងក្រុងភ្នំពេញ ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៨ នៅឯមជ្ឈមណ្ឌលវប្បធម៌បារាំង។

លោកបានបន្តទៀតថា នេះជាមហោស្រពរូបថតជាតិ និងអន្តរជាតិដែលមានការចូលរួមតាំងពិព័រណ៍ដោយសិល្បៈករខ្មែរ ហើយនិងបរទេស ដែលមានចម្រុះជាតិសាសន៍។ ពួកគេក៏បានផ្ដិតយករូបថតមួយផ្នែក ដែលពាក់ព័ន្ធ និងជីវភាព រស់នៅរបស់ប្រជាជនពីខេត្តសៀមរាប និងពីទីក្រុងភ្នំពេញដែរ។

លោកបានបញ្ជាក់ថា : "នៅទីក្រុងភ្នំពេញសិល្បៈករទាំងអស់ ដែលបានពាំនាំយកមកនូវស្នាដៃរបស់ខ្លួន មកចូលរួមសម្រាប់ការតាំងពិព័រណ៍នេះមានទាំងអស់ ១៣រូប មកពី៦ប្រទេស ដោយឡែកនៅសៀមរាបវិញ គឺមានច្រើនរូបជាងនេះ"។

លោកក៏បានបន្តទៀតថា សម្រាប់ការតាំងពិព័រណ៍នៅក្រុងភ្នំពេញសិល្បៈករទាំងអស់ដែលចូលរួម គឺមានខ្មែរជាម្ចាស់ផ្ទះ ចំនួន៤រូប ឥណ្ឌា ថៃ ឥណ្ឌូនេស៊ី និងចិន មួយរូបៗ ដោយឡែកសិល្បៈករមកពីប្រទេសបារាំង នោះមានចំនួន ៤រូប ចំណែកនៅសៀមរាបវិញ គឺមានជាច្រើនរូប។

បើយោងទៅតាមសេចក្ដីប្រកាសព័ត៌មានមួយ បានឱ្យដឹងថា មហោស្រពរូបថត នៅទីក្រុងសៀមរាប សិល្បៈករដែលបានយករូបថតមកចូលរួមសម្រាប់ការតាំងពិព័រណ៍មានប្រមាណទៅដល់ ៦០នាក់ ឯណោះ។ សម្រាប់ការតាំងពិព័រណ៍រូបថត នៅទីក្រុងភ្នំពេញ ត្រូវបានគេចាត់ទុកថា វាជាកម្មវិធីមហោស្រពដែលរៀបចំធ្វើឡើងជាលើកទីមួយ ចំណែកនៅខេត្តសៀមរាបវិញ វាជាមហោស្រពលើកទី៤ ពោលគឺ គេបានរៀបចំដូច្នេះ តាំងតែពីឆ្នាំ២០០៥ មកម្ល៉េះ ។

## អំណាន

### រឿងសច្ចៈ




ហេតុអ្វីបានជានៅក្នុងស្ថានមនុស្សលោក គេឃើញមានបញ្ហាឥតឈប់ឈរ? អស់ពីគ្រោះទុរ្ភិក្សដល់គ្រោះទឹកជំនន់ អស់ពីគ្រោះទឹកជំនន់ដល់រញ្ជួយដី អស់ពីរញ្ជួយដីដល់សង្គ្រាម ហើយអស់ពីសង្គ្រាមដល់ទុរ្ភិក្សវិញ ដដែលជាដដែល...? នេះក៏ពីព្រោះអាទិទេពដែលជាទីពំនឹងរបស់មនុស្ស កំពុងជាប់រវល់ និងរវល់ចូលរួមពិធីអភិសេកបុត្រីព្រះឥន្ទ្រ។ បើស្ដាប់ទៅវាហាក់ដូចជាគ្មានន័យអ្វីទេ។ ប៉ុន្តែរឿងសច្ចៈនឹងពន្យល់អ្នកអានថា ហេតុអ្វីគ្រាន់តែពិធីអភិសេកមួយអាចធ្វើឱ្យពិភពលោកនេះ មានការជ្រួលច្របល់ទាំងនៅស្ថានមនុស្ស និងទាំងនៅស្ថានលើ។

ក្រៅពីអត្ថន័យល្អពិសិដ្ឋ និងដំណោះស្រាយបញ្ហាដ៏ឆ្លាតវៃ រឿងសច្ចៈត្រូវសរសេរឡើងជាមួយនឹងសំណេរថ្មី ដែលគេឃើញដោយកម្រ ក្នុងពិភពអក្សរសិល្ប៍ទំនើបខ្មែរ។

រឿងនេះនិពន្ធដោយឈូក រត្ន័ (ស្នាដៃទទួលរង្វាន់ពីសមូ-ហកម្មអក្សរសិល្ប៍នូ ហាច លេខ២ ឆ្នាំ២០០៥)។

### រឿងម្ចាស់ប្ដីដួងចិត្តអូន




តើមានស្នាដៃអក្សរសិល្ប៍ខ្មែរល្បីៗប៉ុន្មានហើយ ដែលនិយាយអំពីមូលបញ្ហាតែមួយ : បុរសមានវណ្ណៈទន់ទាប បានមានទំនាក់ទំនងស្នេហាជាមួយនារីឋានៈខ្ពង់ខ្ពស់? ជាទូទៅ ឪពុកម្ដាយខាងស្រីមិនយល់ព្រម ព្រោះពួកគាត់ចង់លើកកូនស្រីឱ្យមន្ត្រីធំ ឬអភិជនដោយរកគ្រប់មធ្យោ-បាយ ដើម្បីបំបែកបំបាក់គូស្នេហ៍របស់កូន។ ក្នុងចំណោមរឿងទាំងនោះ ខ្លះបានបញ្ចប់យ៉ាងធូរស្រាល (ចៅស្រទបចេក)។ ខ្លះទៀតក៏បញ្ចប់ដោយព្រាត់ប្រាស់(ទុំទាវ)។

រឿងម្ចាស់ប្ដីដួងចិត្តអូន: តួអង្គគន្លាបានប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងវាសនាដើម្បីរំដោះស្នេហារបស់ខ្លួន។ នេះគឺជាប្រលោមលោកមួយ ដែលសិក្សាយ៉ាងលំអិតអំពីអត្តចរិត និងអារម្មណ៍ឪពុកម្ដាយមួយចំនួន ដែលតំណាងឱ្យប្រជា-ជនខ្មែរមួយភាគធំ។ ពេលដឹងថា កូនស្រីខ្លួនមានផ្ទៃពោះនៅមុនរៀបការ មធ្យោបាយដែលគេប្រើញឹកញាប់បំផុតគឺការរំលូតកូន ដោយយកតួអង្គគន្លាមកធ្វើជាឧទាហរណ៍ (នាងស្លាប់ដោយសារទ្រាំទ្រចំពោះការឈឺចាប់ផ្លូវចិត្តមិនបាន)។ អ្នកនិពន្ធបានពញ្ញាក់អារម្មណ៍ឪពុកម្ដាយឱ្យមើលឃើញពីផលវិបាកនៃការសម្រេចចិត្តរបស់ខ្លួន។ រឿងនេះនិពន្ធដោយលោករស់ ចន្ទ្រាបុត្រ និងលក់ ៤០០០រៀល។

**ហួត សុជាតា**



# ប្រវត្តិសាស្ត្រ

# វៀតណាម ប្រយុទ្ធដើម្បីឯករាជ្យភាព

**អាន ឡូរ៉ំ ប៉ូរ៉េ**



hotos : D

តាមរយៈពាក្យពីរម៉ាត់នៃឈ្មោះរបស់ខ្លួន ប្រទេសវៀតណាមបានយកតាមឈ្មោះសហគមន៍ជនជាតិភាគច្រើនបំផុតនៅក្នុងប្រទេស គឺជនជាតិវៀតនិងបន្ថែមពីលើនេះដោយពាក្យថា "ណាម" ដែលមានន័យ "ខាងត្បូង"។ ប្រទេសនេះ មានអត្តសញ្ញាណរបស់ខ្លួនតាំងតែពីដំបូងដែដោយការប្រឆាំងតទល់នឹងប្រទេសចិនដែលជាអ្នកជិតខាងដែលពោរពេញដោយការរំខាននៅភាគខាងជើង និងបានគ្រប់គ្រងទឹកដីវៀតណាមជិត១០០០ឆ្នាំ។ រយៈពេលនៃការតស៊ូជាបន្តបន្ទាប់ចំពោះវត្តមានរបស់ចិន បង្កើតឱ្យមានរឿងនិទានខ្លីៗ រហូតមកដល់សព្វថ្ងៃនេះ ដែលនិយាយអំពីវីរភាពរបស់វីរបុរសវៀតណាម។

ការចាប់កំណើតពិតប្រាកដរបស់វៀតណាម គឺចងភ្ជាប់ទៅនឹងសម័យកាលគ្រងរាជ្យរបស់រាជវង្សលី និងត្រៀនដែលនេះជាយុគសម័យមាស។ ការលុកលុយរបស់ម៉ុងហ្គោល ត្រូវវៀតណាមបានវាយរុញច្រានត្រឡប់ទៅវិញ។ ហើយសាសនាព្រះពុទ្ធត្រូវបានផ្សព្វផ្សាយពាសពេញប្រទេស។

រាជវង្សឡេ នៅសតវត្សរ៍ទី១៥ បានបង្កើតឱ្យមានយុគសម័យនៃការចម្រើនរុងរឿងថ្មីមួយ។ ក្រោយពីសម័យនេះ មានការចម្បាំងច្បាមយកអំណាចពីវង្សត្រកូលគ្រួសារផ្សេងៗ។ វង្សត្រកូលត្រឹង បានសោយរាជ្យនៅភាគខាងជើង និងង្វៀង ក៏សោយរាជ្យនៅភាគខាងត្បូង។ ត្រកូលទាំងពីរបាននាំមកនូវសង្គ្រាមជាច្រើនទស្សវត្សរ៍ ហើយនៅភាគខាងត្បូង មានការវាតទីយកដីសណ្ដទន្លេមេគង្គ។ គឺនៅយុគសម័យនោះដែរប្រជាជាតិចម្ប៉ា និងផ្នែកមួយនៃទឹកដីខ្មែរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធជាមួយនឹងប្រទេសវៀតណាម។

តាមពិតត្រកូលង្វៀង ដែលនៅទីចុងបញ្ចប់បង្រួបបង្រួមប្រទេសជាតិបាននោះ មួយផ្នែកដោយសារបានជំនួយពីប្រទេសបារាំង។ ប៉ុន្តែបន្ទាប់មកបារាំងក៏បានកេងយកចំណេញ ដោយវាយកាន់កាប់ទឹកដីវៀតណាមដែលបារាំងបានរក្សាការគ្រប់គ្រងទឹកដីនេះរហូតដល់សង្គ្រាមលោកលើកទីពីរ។

ចលនាកុំម្មុយនីស្ត និងជាតិនិយម ហៅថាវៀតមិញ ដែលដឹកនាំដោយលោកហូជីមិញ បានប្រកាសទាមទារឯករាជ្យ តាំងពីឆ្នាំ១៩៤១ សម្រាប់ប្រទេស។

### លោកអ៊ំហូ តួអង្គគន្លឹះ



**កើតនៅឆ្នាំ១៨៩០ លោកហូ ជីមិញ គឺជាសាស្ត្រាចារ្យ មុនពេលភៀសខ្លួនពីប្រទេសវៀតណាមនៅអាយុ ២១ឆ្នាំ ទៅកាន់សហរដ្ឋអាមេរិក និងអឺរ៉ុប។ នៅបារាំង លោកគឺជាស្ថាបនិកនៃគណបក្សកុំម្មុយនីស្តបារាំង។ នៅឆ្នាំ១៩៣០ គាត់បានបង្កើតគណបក្សកុំម្មុយនីស្តឥណ្ឌូចិន និងបន្ទាប់មកបង្កើតចលនាឯករាជ្យ។ អ្នកដឹកនាំនយោបាយដ៏ល្បីល្បាញបំផុតនៅក្នុងប្រទេសរូបនេះបានស្លាប់នៅឆ្នាំ១៩៦៩។ ឈ្មោះរបស់លោកត្រូវបានប្រសិទ្ធនាមទៅឱ្យទីក្រុងសាយហ្គន (ព្រៃនគរ) នៅពេលប្រទេសត្រូវបានបង្រួបបង្រួមឡើងវិញ។**

នៅឆ្នាំ១៩៤៥ គាត់ក៏បានវាយដណ្ដើមយកទីក្រុងហាណូយ ហើយប្រកាសរដ្ឋាភិបាលបណ្ដោះអាសន្នមួយឡើង។ ប៉ុន្តែប្រទេសបារាំងនៅតែបន្តសង្គ្រាមប្រឆាំងនឹងវៀតមិញ រហូតដល់បរាជ័យ របស់ពួកគេ នៅសមរភូមិឌៀនបៀនភូ ឆ្នាំ១៩៥៤។ ប៉ុន្មានខែក្រោយមក កិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងហ្សឺណែវ (ប្រទេសស្វីស) បានកាត់វៀតណាម ជាពីរផ្នែក : នៅភាគខាងជើងគ្រប់គ្រងដោយលោកហូជីមិញ។ ភាគត្បូងស្ថិតក្រោមការគ្រប់គ្រងរបស់លោកង៉ោ ឌិនឌៀម។

ក្នុងបរិបទនៃសង្គ្រាមត្រជាក់ ភាគីទាំងពីរប្រឈមមុខដាក់គ្នា។ វៀតណាមភាគខាងជើង ទទួលបានការគាំទ្រពីបណ្ដាប្រទេសកុំម្មុយនីស្ត និងភាគខាងត្បូង ទទួលការគាំទ្រពីអាមេរិក។ នៅឆ្នាំ១៩៧៣ បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស អាមេរិកបានដកខ្លួនថយ។ នៅឆ្នាំ១៩៧៥ ភាគខាងជើងក៏បានវាយដណ្ដើមយករដ្ឋធានីភាគខាងត្បូង គឺក្រុងសាយហ្គន(ព្រៃនគរ) និងបង្រួបបង្រួមប្រទេស។ នៅឆ្នាំ១៩៨៦ គណបក្សកុំម្មុយនីស្តវៀតណាមបានបើកទ្វារប្រទេស ទៅកាន់សេដ្ឋកិច្ចទីផ្សារ។ ហើយចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសវៀតណាមបានទទួលនូវការរីកចម្រើនសេដ្ឋកិច្ចយ៉ាងខ្លាំងក្លា និងត្រូវបានគេរាប់បញ្ចូលក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ដែលមានថាមពលបំផុត។

December-2008.qxd 11/27/2008 6:09 PM Page 16

# ល្បែងកំសាន្ត

**ផាត់ពណ៌**

*ចូរប្អូនៗ ផាត់ពណ៌នៅលើរូបខាងក្រោមនេះ ដើម្បីយកទៅបិទលើវត្ថុសំណព្វចិត្តរបស់ប្អូនៗ។*

ជំនួយគំនិត : ទំព័រ៣



សូមថ្លែងអំណរគុណដល់អង្គការស៊ីប៉ាដែលជួយឧបត្ថម្ភទំព័រនេះ។
អង្គការស៊ីប៉ា : ប្រអប់សំបុត្រ ៣១ ផ្ទះលេខ៩ ផ្លូវ២១ រាជធានីភ្នំពេញ-កម្ពុជា ឬទូរស័ព្ទ : ០២៣ ២១៦ ០០១។

## ជ័យលាភីប្រឡងគំនូរកុមារ!



លេខ ១

រិន សុផាត មកពីសាលាឡាវ៉ាឡា



លេខ ២

ហឿន សុម៉ាលី មកពីសាលាឡាវ៉ាឡា



លេខ ៣

ឃិន ស៊ាងហួត មកពីព្រះសហគមន៍កំពង់ធំ

### រង្វាន់លើកទឹកចិត្ត

១- ខឿន ភាលៃ មកពីសាលាឡាវ៉ាឡា
២- សួន ឡៃសៀក មកពីព្រះសហគមន៍កំពង់ធំ
៣- រិទ្ធ ធីតា មកពីព្រះសហគមន៍កំពង់ធំ
៤- ជូ ជុំ មកពីសាលាឡាវ៉ាឡា
៥- រ៉ៃន សុភ័ណ្ឌ មកពីសាលាឡាវ៉ាឡា
៦- រ៉ូត ធី មកពីសាលាឡាវ៉ាឡា
៧- ហេង ស្រីតូច មកពីព្រះសហគមន៍កំពង់ធំ

សូមបញ្ជាក់ : រង្វាន់របស់ប្អូនៗ នឹងទទួលបានពីអ្នកទទួលខុសត្រូវនៅកន្លែងប្អូន។ អ្នកនាំសារនិងផ្ញើទៅនៅពេលក្រោយ។

## ការងារប្រចាំខែ

- នៅដើមខែធ្នូ : មានការដាក់ប្រអប់ប្រមូលថវិកាដើម្បីជួយដល់អ្នកក្រីក្រនៅព្រះសហគមន៍ក្រុងព្រះសីហនុ។
- នៅក្នុងខែធ្នូ : ព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច) នៅភ្នំពេញ មានរៀបចំអភិបូជានៅរៀងរាល់ថ្ងៃអង្គារ៍ វេលាម៉ោង ៦ល្ងាច។
- នៅក្នុងខែធ្នូ : មានពិធីសម្ពោធសាលាមត្តេយ្យនៅព្រះសហគមន៍បឹងតាព្រហ្មក្រុងកំពង់សោម រៀបចំដោយលោកបូជាចារ្យវិរជ័យ។
- ថ្ងៃទី១-៦ ខែធ្នូ : គ្រីស្តបរិស័ទនៅកំពង់ចាមទៅសំណាក់ធម៌នៅព្រះសហគមន៍កោះរកា។
- ថ្ងៃទី១០ ខែធ្នូ : ក្រុមយុវជននៅព្រះសហគមន៍សន្តយ៉ូសែបទៅសំណាក់ធម៌នៅព្រះវិហារបឹងទំពុន រាជធានីភ្នំពេញ។
- ថ្ងៃទី១៣-១៤ ខែធ្នូ : ក្រុមមណ្ឌលសកម្មភាពភ្នំពេញ មានរៀបចំធ្វើសិក្ខាសាលាមួយនៅព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច) រាជធានីភ្នំពេញ។ ថ្ងៃទី១ និយាយអំពីការឆ្លុះបញ្ចាំងខ្លួនឯង និងបេសសកម្មរបស់យុវជនក្នុងព្រះសហគមន៍។ ថ្ងៃទី២ និយាយពីការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់។
- ថ្ងៃទី២០ ខែធ្នូ : គ្រីស្តបរិស័ទ រួមនិងលោកបូជាចារ្យវិរជ័យនៅព្រះសហគមន៍ក្រុងព្រះសីហនុ នឹងធ្វើការចុះសាកសួរសុខទុក្ខទណ្ឌិត ២៥០នាក់ ដែលជាប់ពន្ធនាគារក្រុង។
- ថ្ងៃទី២២ ខែធ្នូ : ព្រះសហគមន៍ខេត្តកំពត រៀបចំការចុះសួរសុខទុក្ខទណ្ឌិតនៅក្នុងពន្ធនាគារខេត្តដោយមានតំណាងពីអន្តរសាសនា និងតំណាងរាជរដ្ឋាភិបាលចូលរួមផងដែរ។
- ថ្ងៃទី២៤ ខែធ្នូ : មានរៀបចំអភិបូជាបុណ្យចម្លងនៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) ភ្នំពេញ វេលាម៉ោង ៦ល្ងាច។
- ថ្ងៃទី២៤ ខែធ្នូ : អភិបូជាបុណ្យចម្លងនៅព្រះសហគមន៍ក្រុងព្រះសីហនុ។
- ថ្ងៃទី២៤ ខែធ្នូ : អភិបូជាបុណ្យចម្លងនៅព្រះសហគមន៍សៀមរាប។
- ថ្ងៃទី២៤-២៦ ខែធ្នូ : អភិបូជាបុណ្យចម្លងនៅព្រះសហគមន៍បាត់ដំបង។
- ថ្ងៃទី២៥ ខែធ្នូ : អភិបូជាបុណ្យចម្លងនៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច)ដដែល ប៉ុន្តែគេវេលាម៉ោង ៩ព្រឹក។
- ថ្ងៃទី២៧ ខែធ្នូ : អភិបូជាបុណ្យចម្លងនៅព្រះសហគមន៍កំពត។